# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤១ សហណ.កបច

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥

## I- បរិការណ៍ទូទៅ

**១**- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា កំពុងបន្តជំរុញអនុវត្តយ៉ាងសស្រាក់សស្រាំនូវបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយនិងកាន់តែស្វាហាប់ ឆ្លើយតបនឹងក្តីប្រាថ្នារបស់ប្រជាជន ក៏ដូចជាសំដៅពន្លឿនកិច្ចអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងកិច្ចការកែទម្រង់ កាន់តែស៊ីជម្រៅនិងទូលំទូលាយលើគ្រប់វិស័យ ដើម្បីបន្តឈានទៅដំណាក់កាលអភិវឌ្ឍន៍ថ្មីមួយទៀត គឺប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ។ ឈរលើមូលដ្ឋាននេះ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ មានគោលដៅបន្តគាំទ្រការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការគន្លឹះនានា ដែលត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ចាប់ពីដើមនីតិកាលទី៧នៃរដ្ឋសភា ឱ្យសម្រេចបាននូវលទ្ធផលផ្លែផ្កាជាអតិបរមា ដើម្បីឆ្លើយតបទៅនឹងសំណូមពរ សេចក្តីត្រូវការ និងការរំពឹងទុករបស់ប្រជាជនកម្ពុជាដែលជាម្ចាស់ឆ្នោត។ ទន្ទឹមនេះ ក្នុងបរិការណ៍ដែលកម្ពុជាកំពុងទទួលផលពីសន្តិភាព និងស្ថេរភាពនយោបាយក្នុងប្រទេស ហើយសេដ្ឋកិច្ចក៏កំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតីក្រោយវិបត្តិនៃជំងឺកូវីដ-១៩ កម្ពុជា ក៏ដូចជាប្រទេសឯទៀតលើសកលលោកដែរកំពុងត្រូវបានបន្តហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ដែលជាប្រការអាចយាយីដល់កិច្ចខិតខំប្រឹងប្រែងក្នុងការបន្តអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ខ្លួនដើម្បីឈានទៅដំណាក់កាលថ្មីទៀត។

**២**- រយៈពេលមធ្យមខាងមុខ គឺជាអន្តរកាលដ៏សំខាន់របស់កម្ពុជាក្នុងដំណើរឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ ក្នុងក្របខ័ណ្ឌនេះ កម្ពុជាពិតជាត្រូវការនូវប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែស្អាតស្អំ ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ដើម្បីអាចដោះស្រាយបញ្ហាសង្គមនិងសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាពខ្ពស់ សម្រាប់ទ្រទ្រង់ដល់ដំណើរការបរិវត្តកម្មស៊ីជម្រៅ

ដូចបានគូសបញ្ជាក់ខាងលើ។ ក្នុងគោលដៅនេះដែរ កម្ពុជាត្រូវខិតខំសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ជុំវិញ៦-៧% ដើម្បីបង្កើតការងារប្រកបដោយគុណភាពសម្រាប់យុវជនផង និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះក្ដីរំពឹងទុករបស់ប្រជាជនផង ក៏ដូចជាឆ្លើយតបនឹងសេចក្ដីត្រូវការរបស់ប្រជាជនដែលចេះតែកើនឡើងជាលំដាប់នូវសេវាសាធារណៈសំខាន់ៗ ប្រកបដោយគុណភាព ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សេវាអប់រំ សេវាសុខាភិបាល និងសេវាមូលដ្ឋានចាំបាច់ផ្សេងទៀត រួមទាំង របបសន្តិសុខសង្គម របបជំនួយសង្គម និងសុខុមាលភាពរបស់ប្រជាជនទូទៅការធានាសុវត្ថិភាពចំណូល ជាពិសេសសម្រាប់ប្រជាជនងាយរងគ្រោះ និងការកាត់បន្ថយគម្លាតនៃការរីកចម្រើនរវាងទីក្រុងនិងជនបទ។ ទន្ទឹមនេះ កម្ពុជាក៏ត្រូវត្រៀមលក្ខណៈឱ្យបានសមស្របក្នុងការទប់ទល់នឹងផលប៉ះពាល់ពីកត្តាខាងក្រៅប្រទេស ដែលមានជាអាទិ៍ : ការកើនឡើងនូវភាពតានតឹងភូមិសាស្ត្រនយោបាយតំបន់និងសកល ជាពិសេសការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន សង្គ្រាមរវាងអ៊ីស្រាអែលនិងក្រុមហាម៉ាស រួមទាំងលទ្ធភាពនៃការផ្ទុះឡើងក្នុងទ្រង់ទ្រាយធំនៃជម្លោះនៅតំបន់សមុទ្រក្រហម ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងអាចរុញច្រានថ្លៃទំនិញអន្តរជាតិឱ្យហក់ឡើងវិញ ការបែកខ្ញែកនៃសេដ្ឋកិច្ចសកលដែលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការនិងពាណិជ្ជកម្មអន្តរជាតិ ការបន្តនិន្នាការថមថយនៃកំណើនសេដ្ឋកិច្ចសកល និងភាពមិនច្បាស់លាស់នៃទស្សនវិស័យសេដ្ឋកិច្ចចិន ក៏ដូចជា ការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិ ដែលអាចធ្វើឱ្យប៉ះពាល់ខ្លាំងដល់វិស័យកសិកម្ម និងបង្កឱ្យមានបញ្ហាសន្តិសុខស្បៀង និងការកើនឡើងនៃថ្លៃទំនិញ ជាពិសេសថ្លៃម្ហូបអាហារនិងធាតុចូលកសិកម្មជាដើម។ ជារួម ទស្សនវិស័យសេដ្ឋកិច្ចសកលនៅបន្តត្រូវបានហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ដែលអាចបន្ទច់បង្អាក់ដល់សន្ទុះនៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលខ្លីនិងមធ្យមខាងមុខ។ ពិតណាស់ថា កម្ពុជាដែលជាប្រទេសមានសេដ្ឋកិច្ចបើកចំហខ្លាំងហើយទទួលបានការរីកចម្រើនដោយសារសកលភាវូបនីយកម្ម អាចនឹងទទួលរងនូវផលប៉ះពាល់អវិជ្ជមានពីកត្តាខាងក្រៅ ក៏ប៉ុន្តែជាមួយគ្នានេះ កម្ពុជាក៏អាចនឹងទទួលបាននូវកាលានុវត្តភាពមួយចំនួនវិញដែរក្នុងលក្ខខណ្ឌដែលកម្ពុជាចេះបត់បែន និងតាមទាន់សភាពការណ៍ប្រែប្រួលក្នុងតំបន់និងពិភពលោក ដើម្បីបញ្ចៀសនិងសម្រាលនូវផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយណាដែលអាចកើតមានឡើង ជាយថាហេតុ។ ដូចនេះ កម្ពុជាក៏ត្រូវត្រៀមខ្លួនឱ្យបានល្អក្នុងការប្រែក្លាយបញ្ហាប្រឈមនានាឱ្យទៅជាកាលានុវត្តភាព និងត្រូវចេះប្រើប្រាស់លក្ខខណ្ឌអំណោយផលទាំងឡាយ សម្រាប់លើកកម្ពស់ប្រសិទ្ធភាព និងភាពប្រកួតប្រជែងសេដ្ឋកិច្ច និងកែលម្អបរិស្ថានវិនិយោគ ដើម្បីទទួល និងទាក់ទាញបន្ថែមការវិនិយោគ និងធុរកិច្ច ដែលអាចនឹងហូរចេញពីតំបន់មានជម្លោះពាណិជ្ជកម្មចូលមកកាន់កម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកំពុងរៀបចំដាក់ចេញឱ្យបានមុនដំណាច់ឆ្នាំ២០២៤នេះនូវ «កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង, បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីកំណើនសេដ្ឋកិច្ចនៅក្នុងបរិការណ៍សកលដែលមានភាពមិនប្រាកដប្រជាខ្ពស់សម្រាប់ឆ្នាំ២០២៤-២០២៨»។ ជាងនេះទៀត កម្ពុជាក៏ត្រូវទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើនផ្នែកបច្ចេកវិទ្យានិងឌីជីថលូបនីយកម្ម ជាពិសេសក្នុងបរិការណ៍នៃបដិវត្តឧស្សាហកម្មទី៤ និងត្រូវលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការពារនិងការអភិរក្សបរិស្ថាន ព្រមទាំងត្រូវសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុផងដែរ ។

៣- ក្នុងបរិការណ៍នេះ ថវិកាឆ្នាំ២០២៥ ត្រូវបានគិតគូរនិងរៀបចំឡើង ដើម្បីទ្រទ្រង់និរន្តរភាពនៃកិច្ចប្រតិបត្តិការរបស់ស្ថាប័នរដ្ឋ ជាពិសេសការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការកែទម្រង់គន្លឹះ និងជាក់ស្តែងនានា ដែលត្រូវបន្តអនុវត្តនៅក្នុងឆ្នាំ២០២៥ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស ទាំងក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ជាពិសេសដើម្បីសម្រេចឱ្យបានជាអតិបរមានូវ **គោលដៅជាយុទ្ធសាស្ត្រទាំង៥** ដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេច **ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០** ដែលជា **របៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា** ដោយក្នុងនោះ **មនុស្ស** ត្រូវបានបន្តកំណត់ជាអាទិភាពគន្លឹះទី១ ហើយ **ផ្លូវ ទឹក ភ្លើង** និង **បច្ចេកវិទ្យា** ជាអាទិភាពគន្លឹះបន្តបន្ទាប់តាមលំដាប់ និងមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងទិសដៅនៃការអភិវឌ្ឍកម្ពុជាក្នុងដំណាក់កាលថ្មីខាងមុខ។ ទន្ទឹមនេះ ថវិកាឆ្នាំ២០២៥ ក៏ត្រូវបានរៀបចំឡើងក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទាំង៦ ព្រមទាំងវិធានការគន្លឹះទាំង៥ សម្រាប់ដោះស្រាយបញ្ហាប្រឈមជាអាទិភាពមួយចំនួនដែលត្រូវបានដាក់ចេញដោយ រាជរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំពេញអង្គលើកដំបូងនៃគណៈរដ្ឋមន្ត្រី នីតិកាលទី៧នៃរដ្ឋសភា។

ដូចនេះ ថវិកាឆ្នាំ២០២៥ ត្រូវតែជា "ថវិកានៃការបោះជំហានទៅមុខយ៉ាងស្វាហាប់ ប្រកបដោយឆន្ទៈមោះមុតនិងការប្តូរប្តេជ្ញ ក្នុងការឆ្លងកាត់និងជម្នះលើរាល់បញ្ហាប្រឈម និងឧបសគ្គផងទាំងពួង ឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ក្រោមម្លប់នៃសុខសន្តិភាព ដើម្បីជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយភាពធន់ បរិយាបន្ន និងមានចីរភាព ព្រមទាំងបែងចែកផលនៃកំណើននេះ ប្រកបដោយសមធម៌"។

## II- ក្របខ័ណ្ឌនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥

៤- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៥ ត្រូវបានរៀបចំឡើងជាមួយនឹងការគិតគូរថា សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសេដ្ឋកិច្ចសកលលោកនិងតំបន់ នឹងបន្តដំណើរលើមាគ៌ាស្តារនិងជំរុញកំណើនឡើងវិញ បន្ទាប់ពីទទួលរងការប៉ះទង្គិចផ្ទួនៗពីវិបត្តិបន្តបន្ទាប់ក្នុងឆ្នាំកន្លងមក ប៉ុន្តែកំណើននេះនៅមិនទាន់ឡើងដល់កម្រិតសក្តានុពលនៅឡើយ ទោះបីស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ត្រូវបានរំពឹងទុកថានឹងកាន់តែមានភាពប្រសើរឡើងជាមុន។ ជារួម ទស្សនវិស័យសេដ្ឋកិច្ចត្រូវបានវាយតម្លៃក្រោមសម្មតិកម្មថា ស្ថានភាពសង្គម សេដ្ឋកិច្ចនៃប្រទេសជាដៃគូសំខាន់របស់កម្ពុជានឹងវិវត្តកាន់តែវិជ្ជមាន ហើយភាពតានតឹងខាងគោលនយោបាយរូបិយវត្ថុនិងសារពើពន្ធ នឹងមានភាពធូរស្រាលជាបណ្តើរៗ ដែលនឹងជះឥទ្ធិពលល្អមកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈកម្ពុជា ស្របពេលដែលចលនការនៃការកែទម្រង់ស៊ីជម្រៅក្នុងប្រទេស នឹងបន្តហុចផលជាផ្លែផ្កា និងរួមចំណែកជាវិជ្ជមានដល់ដំណើរការអភិវឌ្ឍន៍។ ទោះជាយ៉ាងនេះក្តី ជវភាព និងនិម្មាបនកម្មសង្គមសេដ្ឋកិច្ចតំបន់និងសកល អាចប្រែប្រួលយ៉ាងឆាប់រហ័ស ដែលនិន្នាការថ្មីនេះ រួមទាំង ហានិភ័យ និងភាពមិនប្រាកដប្រជា ទាំងក្នុងក្របខ័ណ្ឌសកល តំបន់ និងក្នុងស្រុក នៅតែអាចមានការផ្លាស់ប្តូរ និងធ្វើឱ្យសម្មតិកម្មខាងលើប្រែប្រួល ហើយផ្តល់ជាកម្មវិបាកមកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ដែលបានកំណត់នៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់នេះ។

## II-១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០២៥

**៥**- យោងលើការវាយតម្លៃនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០២៥ សេដ្ឋកិច្ចកម្ពុជានឹងបន្តនិន្នាការកើនឡើង ដោយរំពឹងថានឹងសម្រេចបានកំណើនក្នុងរង្វង់៦,៣%ដែលធ្វើឱ្យផ.ស.ស. ថ្លៃបច្ចុប្បន្នស្ថិតក្នុងរង្វង់២០៩ ១៦៣ប៊ីលានរៀល សមមូលនឹងប្រមាណ៥១ ៣៩៨លានដុល្លារអាមេរិក ស្របពេលដែលផ.ស.ស. សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថានឹងកើនឡើងដល់២ ៩២៤ដុល្លារអាមេរិក បើធៀបនឹងប្រមាណ២ ៧១៣ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤។ ការរំពឹងទុកនូវកំណើន៦,៣%នេះ ត្រូវបានគាំទ្រដោយវិស័យសេដ្ឋកិច្ចសំខាន់ៗ ដូចខាងក្រោម៖

**ទី១- វិស័យឧស្សាហកម្ម ត្រូវបានព្យាករថានឹងមានកំណើន៨,៦% ក្នុងឆ្នាំ២០២៥** ដែលគាំទ្រដោយការរក្សាបានតុល្យភាពនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈអនុវិស័យសំណង់នៅបន្តមានកំណើនទាបជាងនិន្នាការធម្មតា (មុនវិបត្តិជំងឺកូវីដ-១៩)។ **អនុវិស័យកាត់ដេរ** ត្រូវបានរំពឹងថានៅបន្តរក្សាបានកំណើនប្រហាក់ប្រហែលមុនវិបត្តិជំងឺកូវីដ-១៩ ដោយសារភាពប្រសើរនៃតម្រូវការសកល គួបផ្សំនឹងការពង្រឹងការអនុវត្ត «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**» ដែលនឹងលើកកម្ពស់បរិយាកាសវិនិយោគ និងភាពប្រកួតប្រជែងជាមួយនឹងការបង្កើនផលិតភាពពលកម្ម។ ជាមួយគ្នានេះ **អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ** ត្រូវបានព្យាករថានឹងបន្តរក្សាបានកំណើនរឹងមាំ ដោយសារការរំពឹងពីការបន្តកើននៃតម្រូវការខាងក្រៅ ដែលនឹងបន្តជំរុញការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ស្របពេលដែលឧស្សាហកម្មបម្រើឱ្យទីផ្សារក្នុងស្រុក ត្រូវបានរំពឹងថានឹងបន្តកើនក្រោមការដាក់ចេញនូវវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល សំដៅជំរុញសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព។ ស្របគ្នានេះ **អនុវិស័យផលិតកម្មម្ហូបអាហារ និងភេសជ្ជៈ** ក៏ត្រូវបានព្យាករថានឹងបន្តកំណើនល្អ។ ទោះជាយ៉ាងនេះក្តី **អនុវិស័យសំណង់** ត្រូវបានព្យាករថាបន្តកំណើនទាបជាងនិន្នាការធម្មតា ដោយសារការរំពឹងពីការងើបវិញយឺតនៃលំហូរវិនិយោគទុនពីបរទេស ជាពិសេសសំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ស្របពេលដែលសំណង់លំនៅឋាន ត្រូវបានរំពឹងថាបន្តរក្សាកំណើនទាប ធៀបនឹងនិន្នាការមុនវិបត្តិជំងឺកូវីដ-១៩។ ក្នុងរយៈពេលមធ្យមខាងមុខ អនុវិស័យនេះនឹងជំរុញដោយសកម្មភាពសំណង់ដែលចេញពីតម្រូវការពិត ជាពិសេសផ្នែកលំនៅឋាន ដែលគាំទ្រដោយសារភាពប្រសើរនៃកត្តាកាគលាភប្រជាសាស្ត្រកម្ពុជា ខណៈដែលសំណង់បម្រើឱ្យឧស្សាហកម្ម រោងចក្រ និងសកម្មភាពពាណិជ្ជកម្មផ្សេងទៀត ក៏នឹងក្លាយជានិន្នាការថ្មីមួយជួយទ្រទ្រង់វិស័យនេះក្នុងរយៈពេលខ្លីនិងមធ្យមខាងមុខ។

**ទី២- វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងមានកំណើន៥,៦% ក្នុងឆ្នាំ២០២៥** ដោយសារការបន្តរក្សាបានចលនការនៃអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត ខណៈដែលអនុវិស័យអចលនទ្រព្យនៅបន្តមានកំណើនទាប។ **អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ** ត្រូវបានរំពឹងថានឹងបន្តកើន គាំទ្រដោយកំណើនភ្ញៀវទេសចរអន្តរជាតិ ខណៈភ្ញៀវទេសចរជាតិនៅបន្តមានសក្តានុពល។ ការបន្តអនុវត្តនូវ «**ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩**», «**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥**» និង «**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរីឆ្នាំ២០២១-២០៣៥**» ព្រមទាំងកម្មវិធី «ទស្សនាសៀមរាប២០២៤» នឹងចូលរួមចំណែក

យ៉ាងសំខាន់ក្នុងការស្តារនិងជំរុញកំណើនវិស័យទេសចរណ៍ឡើងវិញ។ **អនុវិស័យអចលនទ្រព្យ** ត្រូវបានរំពឹងថានឹងកើនក្នុងអត្រាទាបជាងធម្មតា ដោយសារការរំពឹងទុកនៃការបន្តងើបវិញយឺតនៃលំហូរទុនវិនិយោគពីបរទេស ប៉ុន្តែសកម្មភាពទិញ-លក់អចលនទ្រព្យ ជាពិសេសផ្នែកលំនៅឋានថ្លៃទាប និងមធ្យម ត្រូវបានរំពឹងថានឹងបន្តគាំទ្រដល់កំណើននៃអនុវិស័យនេះជារួម។**អនុវិស័យលក់ដុំ-រាយ** ត្រូវបានព្យាករថានឹងបន្តកើនប្រហាក់ប្រហែលទៅនឹងនិន្នាការធម្មតា ដោយសារការរំពឹងទុកពីការងើបវិញនៃសកម្មភាពចាយវាយនិងតម្រូវការក្នុងស្រុក ស្របជាមួយនឹងនិន្នាការនៃការកើនប្រាក់ចំណូលរបស់ប្រជាជន។ ការផ្លាស់ប្តូររបៀបរបបអាជីវកម្មតាមរយៈការប្រើប្រាស់ថ្នាលឌីជីថល នឹងអាចជួយលើកកម្ពស់បន្ថែមទៀតដល់អនុវិស័យនេះជារួម។ **អនុវិស័យដឹកជញ្ជូន និងស្តុក** ត្រូវបានរំពឹងថានឹងបន្តកំណើនរឹងមាំ ដោយសកម្មភាពដឹកជញ្ជូនកាន់តែមានភាពមមាញឹក ជាពិសេស ការដឹកជញ្ជូន ទំនិញក្នុងស្រុក និងការដឹកជញ្ជូនទំនិញគោលដៅចុងក្រោយដល់អ្នកប្រើប្រាស់។ ទន្ទឹមនេះ ការដាក់ចេញនូវចក្ខុវិស័យក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមមាន ផ្លូវអាកាស ផ្លូវទឹក និងផ្លូវគោក តាមរយៈ **«ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយនិងកស្តុភារកម្មកម្ពុជា២០២៣-២០៣៣»** នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើននៃអនុវិស័យនេះ។ **អនុវិស័យហិរញ្ញវត្ថុនិងធានារ៉ាប់រង** នៅបន្តរក្សាបានចលនការល្អដែលគាំទ្រដោយការបន្តធ្វើទំនើបកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ សំដៅបម្រើដល់តម្រូវការប្រជាជននិងអាជីវកម្ម ខណៈដែលការអនុវត្ត «គោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨» និង «យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥» នឹងដើរតួនាទីសំខាន់ក្នុងការបន្តជំរុញការធ្វើទំនើបកម្មនិងបរិយាបន្នវិស័យហិរញ្ញវត្ថុ ទាំងផ្នែកធនាគារនិងមិនមែនធនាគារ។ **អនុវិស័យបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍** ត្រូវបានព្យាករថាបន្តកើនប្រហាក់ប្រហែលទៅនឹងនិន្នាការនៃប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការបន្តកើននៃសកម្មភាពប្រើប្រាស់អ៊ីនធឺណិតនិងការផ្តល់សេវានូវដំណោះស្រាយបច្ចេកវិទ្យាថ្មី ស្របជាមួយនឹងការបន្តអនុវត្ត «គោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨», «គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥» «ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥» ។ល។

**ទី៣- វិស័យកសិកម្ម** ត្រូវបានព្យាករថាកើនឡើង**១,១%** **ក្នុងឆ្នាំ២០២៥** ដោយសារការរំពឹងទុកនូវកំណើនល្អនៃអនុវិស័យដំណាំនិងចិញ្ចឹមសត្វ និងការងើបសន្សឹមៗនៃអនុវិស័យនេសាទ។ អនុវិស័យដំណាំ ត្រូវបានរំពឹងថានៅរក្សាកំណើនល្អ ដោយសារការបន្តកើននៃការវិនិយោគ ទាំងក្នុងស្រុកនិងពីបរទេស លើការកែច្នៃផលិតផលកសិកម្ម ការបង្កើនការវិនិយោគសាធារណៈ និងអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដូចជា : ការផ្តល់ហិរញ្ញប្បទានសម្បទាន ក្នុងការជំរុញផលិតកម្មក្នុងស្រុកនិងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ដែលនឹងបន្តជំរុញដល់ការនាំចេញ។ ទន្ទឹមនេះ អនុវិស័យចិញ្ចឹមសត្វត្រូវបានព្យាករថានឹងបន្តងើបសន្សឹមៗ ដោយសារវិធានអន្តរាគមន៍របស់រាជរដ្ឋាភិបាលលើការនាំចូលសាច់បង្កក ដែលនឹងលើកទឹកចិត្តការចិញ្ចឹមក្នុងស្រុក ខណៈអនុវិស័យនេសាទត្រូវបានព្យាករថានឹងមានកំណើនល្អ ក្រោមការរំពឹងទុកនូវកំណើនផលចាប់ទឹកសាបដែលនឹងត្រូវបានបន្តស្តារឡើងវិញ ដោយសារការដាក់ចេញនូវគោលនយោបាយបង្ក្រាបបទល្មើសនេសាទ និងការវិនិយោគក្នុងវារីវប្បកម្ម ក្រោមការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាលនិងការគាំទ្រពីដៃគូអភិវឌ្ឍន៍ សំដៅដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ ផ្តល់ការគាំទ្រផ្នែកហិរញ្ញប្បទាន និងជំរុញការផ្សព្វផ្សាយបច្ចេកទេសនិងការប្រើប្រាស់ពូជត្រី ប្រកបដោយប្រសិទ្ធភាពខ្ពស់និងគុណភាព។

អត្រាអតិផរណាជាមធ្យមប្រចាំឆ្នាំ ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់២,៥% ក្នុងឆ្នាំ២០២៥ ដោយសារការរក្សាបាននូវចលនការសេដ្ឋកិច្ចក្នុងស្រុក និងប្រក្រតីភាពនៃស្ថានភាព និងថ្លៃទំនិញអន្តរជាតិ។ យ៉ាងណាមិញ ហានិភ័យដែលបង្កឡើងដោយភាពមិនប្រាកដប្រជាមួយចំនួន ដូចជាភាពកាន់តែតានតឹងនៃភូមិសាស្ត្រនយោបាយនិងភូមិសាស្ត្រសេដ្ឋកិច្ច នឹងអាចធ្វើឱ្យអត្រាអតិផរណាហក់ឡើងមកវិញ ដោយសារកត្តាផ្គត់ផ្គង់។

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ត្រូវបានរំពឹងថារក្សាបានក្នុងរង្វង់៤ ០៦៩រៀល/ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៥ ដោយសារការបន្តអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។

ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា-២,៦% ដោយសារការរំពឹងទុកពីការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ក៏នៅបន្តមាននិន្នាការល្អ។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើនក្នុងរង្វង់ជាមធ្យមប្រមាណ៨,៦% នៃផ.ស.ស. ដោយសារការបន្តកើននូវទំនុកចិត្តពីវិនិយោគិន ជាមួយនឹងបរិយាកាសកាន់តែអំណោយផលសម្រាប់ការវិនិយោគនៅកម្ពុជា តាមរយៈការអនុវត្ត «ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា» និងគោលនយោបាយគាំទ្រមួយចំនួនទៀត ជាពិសេសទៅលើការវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់។

ទុនបម្រុងអន្តរជាតិសរុប ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់២៤ ៤២៣លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៥ និងជានាការនាំចូលបាន៧,៥ខែ។

**៦**- ក្នុងន័យនេះ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០២៥ ត្រូវបានកំណត់តាមសូចនាករសំខាន់ៗដូចខាងក្រោម៖

| **សូចនាករសេដ្ឋកិច្ច** | **២០២៣** | **២០២៤** | **២០២៥** |
|---|---|---|---|
| | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ព្យាករ |
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ១៧៧ ០៣៦ | ១៩២ ០០៥ | ២០៩ ១៦៣ |
| កំណើន ផ.ស.ស. ពិត (%) | ៥,០% | ៦,០% | ៦,៣% |
| ផ.ស.ស. សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ២ ៥២០ | ២ ៧១៣ | ២ ៩២៤ |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | ២,១% | ២,៧% | ២,៥% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាមេរិក) | ៤ ១១០ | ៤ ០៨៣ | ៤ ០៦៩ |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃផ.ស.ស.) | ១,៣% | -១,៥% | -២,៦% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ១៩ ៩៩៨ | ២២ ៣០៣ | ២៤ ៤២៣ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៨,២ | ៨,០ | ៧,៥ |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ២០២៣) និង ការព្យាករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខែមេសា ឆ្នាំ២០២៤*

**៧**- បើទោះបីជាសេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ២០២៥ ត្រូវបានរំពឹងថានឹងបន្តងើបឡើងវិញក្នុងអត្រាកំណើន៦,៣% យ៉ាងណាក្តី ភាពមិនប្រាកដប្រជាពី **កត្តាខាងក្រៅ** អាចនឹងបង្កប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ចដោយផ្ទាល់និងប្រយោល ដោយសារកម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចតូចហើយបើកចំហ និងមានការផ្សារភ្ជាប់កាន់តែខ្លាំងជាមួយច្រវាក់ផលិតកម្មក្នុងតំបន់និងពិភពលោក។ ក្នុងន័យនេះ

សេដ្ឋកិច្ចកម្ពុជាអាចនឹងជួបប្រឈមនឹងហានិភ័យនិងភាពមិនប្រាកដប្រជាមួយចំនួនរួមមាន : ១). កំណើនថមថយនៃសេដ្ឋកិច្ចសកលនិងសេដ្ឋកិច្ចចិន ២). ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល ៣). ភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយដែលអាចបន្ទប់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកលនិងនាំទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ ៤). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និង៥). ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិ។ ចំពោះកត្តាខាងក្នុង កម្ពុជាក៏នៅតែបន្តប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួន ដែលធ្វើឱ្យការធ្វើពិពិធកម្មសេដ្ឋកិច្ចមានសភាពយឺតយ៉ាវ និងភាពប្រកួតប្រជែងមានកម្រិត រួមមាន : ១)-ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់ធៀបនឹងប្រទេសមួយចំនួននៅក្នុងតំបន់ ២)-ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្មនិងបរិយាកាសធុរកិច្ច ៣)-បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ៤)-ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាលនិងប្រព័ន្ធគាំពារសង្គម និង ៥)-ភាពមានកម្រិតនៃចំណេះដឹងនិងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។ បន្ថែមលើនេះ កម្ពុជាក៏កំពុងប្រឈមនឹងហានិភ័យនៃការកើនឡើងខ្ពស់នៃបំណុលឯកជនផងដែរ ដែលការណ៍នេះអាចនឹងបង្កើតជាផលជះដល់កំណើននៃវិស័យពិត តាមរយៈការផ្សារភ្ជាប់នៃវិស័យម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៨**- ជាមួយគ្នានេះ ការលេចឡើងនូវនិន្នាការថ្មីៗ តម្រូវឱ្យកម្ពុជាខិតខំពង្រីកនិងបន្តពង្រឹងមូលដ្ឋានខាងក្នុងឱ្យកាន់តែមានភាពប្រកួតប្រជែង ដើម្បីស្រូបនិងទាញយកប្រយោជន៍ពីកាលានុវត្តភាពថ្មីៗទាំងនោះ ក៏ដូចជាបន្តកសាងភាពធន់នៃសង្គម សេដ្ឋកិច្ច ដើម្បីអាចមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការបញ្ចៀសហានិភ័យដែលនឹងកើតឡើងក្នុងពេលខាងមុខជាយថាហេតុ។ ជាការពិត រាជរដ្ឋាភិបាលប្រហែលជាមិនអាចទាយទុកជាមុន និងត្រៀមនូវគ្រប់សេណារីយ៉ូគោលនយោបាយ និងវិធានការជាក់ស្តែងសម្រាប់ដោះស្រាយនូវរាល់បញ្ហាប្រឈមនិងហានិភ័យទាំងឡាយ ដែលអាចកើតមានឡើងដោយពិបាកប៉ាន់ស្មានបាននិងដោយមិនចំណុះនឹងការគ្រប់គ្រងរបស់កម្ពុជានោះឡើយ។ ដូចនេះ ក្នុងការគ្រប់គ្រងសភាពការណ៍ រាជរដ្ឋាភិបាលនឹងប្រកាន់យកនូវអភិក្រម២ទន្ទឹមគ្នា រួមមាន : ម្ខាងតាមដានសិក្សា និងវាយតម្លៃជាប់ជាប្រចាំលើដំណើរការវិវត្តនៃស្ថានការណ៍ខាងក្រៅនិងផ្ទៃក្នុងប្រទេស ពោលគឺត្រូវក្តាប់ជាប់ជាប្រចាំនូវជីពចរនៃសេដ្ឋកិច្ចនិងសង្គម និងត្រូវដាក់ចេញដោយបុរេសកម្មនិងទាន់ពេលនូវវិធានការចាំបាច់ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហាប្រឈមនិងហានិភ័យទាំងឡាយដែលកើតមានចំពោះមុខ ពិសេសវិធានការសំដៅធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពវិស័យហិរញ្ញវត្ថុ និងលំនឹងនៃជីវភាពប្រជាជន និងម្ខាងទៀត ហ៊ានវះកាត់ និងដាក់ចេញនូវវិធានការដាក់លាក់មុតស្រួចនិងចំគោលដៅ ដើម្បីដោះស្រាយបញ្ហាជាឧបសគ្គរាំងស្ទះទាំងឡាយ សំដៅលើកកម្ពស់ភាពប្រកួតប្រជែង និងពង្រឹងភាពធន់ ដើម្បីទាក់ទាញនិងជំរុញការវិនិយោគ និងជំរុញសកម្មភាពសេដ្ឋកិច្ចជាទូទៅ។ ក្នុងនោះ ទស្សនវិជ្ជារួមនៃសកម្មភាពគោលនយោបាយរាជរដ្ឋាភិបាល គឺ **សង្ឃឹមសម្រាប់ស្ថានភាពប្រសើរ តែត្រៀមខ្លួនសម្រាប់ស្ថានភាពអាក្រក់** ដែលលើមូលដ្ឋាននេះ កម្ពុជានឹងអាចតស៊ូដើម្បីរស់រានបាន ខណៈដែលសភាពការណ៍វិវត្តទៅអាក្រក់ ហើយនឹងអាចសម្រេចបានលទ្ធផលកាន់តែប្រសើរនៅពេលសភាពការណ៍វិវត្តទៅល្អ។

ដូចនេះ ជាទិសដៅយុទ្ធសាស្ត្រនិងគោលនយោបាយ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ព្រមទាំងពង្រឹងការកសាងភាពធន់នៃសេដ្ឋកិច្ចនិងសង្គម ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ ដោយផ្តោតលើការអនុវត្ត **អាទិភាពចំនួន៦** ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រួមមាន៖

**ទី១- ការអភិវឌ្ឍមូលធនមនុស្ស** ដោយផ្តោតលើ : ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និងការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

**ទី២- ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង** ដោយផ្តោតលើ : ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច និងការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡជីស្ទិក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល ការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ ការពង្រឹងប្រសិទ្ធភាពនិងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ច ពិសេសរួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក និងការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ។

**ទី៣- ការអភិវឌ្ឍវិស័យឯកជន និងការងារ** ដោយផ្តោតលើ : ការអភិវឌ្ឍទីផ្សារការងារ ការលើកស្ទួយសហគ្រាសមីក្រូធុនតូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាពថ្មី និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន ការពង្រឹងការប្រកួតប្រជែង និងការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

**ទី៤- ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន** ដោយផ្តោតលើ : ការធ្វើបរមូបនីយកម្មផលលាភប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម និងការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង។

**ទី៥- ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល** ដោយផ្តោតលើ : ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល និងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។

**ទី៦- ការបន្តពង្រឹងរដ្ឋបាលសាធារណៈ** តាមរយៈការបន្តកែទម្រង់ស្ថាប័នរដ្ឋ ដោយផ្តោតលើការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពក្នុងការអនុវត្តការងារ ការសម្រិតសម្រាំងមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍិល្អ ឱ្យទទួលខុសត្រូវការងារសំខាន់ៗ ព្រមទាំងការលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់ការរបស់ក្រសួង-ស្ថាប័ន ដើម្បីឈានទៅសម្រេចបានរដ្ឋបាលសាធារណៈ ដែលស្អាតស្អំ ឆ្លាតវៃ និងមានសមត្ថភាពខ្ពស់។

## II-២. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈនិងថវិកាឆ្នាំ២០២៥

៩- ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ២០២៥-២០២៧ បានកំណត់នូវជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ វិធានហិរញ្ញវត្ថុសាធារណៈ និងអាទិភាពគោលនយោបាយដែលមានអធិប្បាយលម្អិត នៅក្នុងឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមនេះ ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជារួម ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខាងលើ និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុ

សាធារណៈ ព្រមទាំងក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់ គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យមខាងមុខ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការបន្តអនុវត្ត «ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន» ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម តាមរយៈការចាប់ផ្តើមកសាងទ្រនាប់ថវិកាឡើងវិញ បន្ទាប់ពីបានអនុវត្តគោលនយោបាយវិត្តារកម្មចំណាយក្នុងការអនុវត្ត វិធានការអន្តរាគមន៍សង្គម សេដ្ឋកិច្ចឆ្នាំ ២០២០-២០២៣ ទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតជាសំខាន់លើការបន្តពង្រឹងប្រសិទ្ធភាពថវិកា ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការតាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយតម្រង់ទិសធនធានទៅកាន់មុខសញ្ញាចំណាយដែលជាអាទិភាពចំពោះមុខ ពោលគឺចាយវាយឱ្យចំទិសដៅ និងធានាបានតម្លៃនៃលុយ ព្រមជាមួយនឹងការខិតខំពង្រឹងការប្រមូលចំណូលឱ្យបានកាន់តែប្រសើរ ដោយមានការថ្លឹងថ្លែងជាមួយនឹងការបន្តរក្សាឱ្យបាននូវចលនការនិងសម្ទុះនៃសកម្មភាពសេដ្ឋកិច្ច ហើយខិតខំចៀសវាងឱ្យបានជាអតិបរមានូវវិការភាពសេដ្ឋកិច្ច។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការពន្ធដែលមានការកែទម្រង់ស៊ីជម្រៅទៅលើផ្នែករដ្ឋបាល និងទំនើបកាវូបនីយកម្មពន្ធ ក្រោមអភិក្រមមិនបង្កើតបន្ទុកពន្ធថ្មី ដោយថ្លឹងថ្លែងការរក្សាបាននូវចលនការសេដ្ឋកិច្ច និងការបន្តបង្កើនចំណូលសម្រាប់តម្រូវការអភិវឌ្ឍន៍ជាតិ។ ចំណែកឯ ការកសាងទ្រនាប់ថវិកា នឹងធ្វើឡើងដោយផ្អែកទៅតាមលទ្ធភាពនៃវឌ្ឍនភាពក្នុងការកៀរគរចំណូល និងការធ្វើវិចារណកម្ម និងការបង្កើនប្រសិទ្ធភាពចំណាយ។

ក្នុងន័យនេះ ស្របតាមអាទិភាពនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៥ បានកំណត់យកអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- បន្តការពារសន្តិភាព ស្ថិរភាពនយោបាយ សមិទ្ធផលសង្គម និងជំរុញការដោះស្រាយបញ្ហាគ្រោះអាសន្ននានា ក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាព និងសុខដុមរមនាប្រជាជន
- បន្តថែរក្សាសមិទ្ធផលនៃការអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់ និងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងពិភពលោក
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងគាំទ្រដល់វិស័យគន្លឹះដែលមានស្រាប់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់
- ជំរុញការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសគ្រប់កម្រិត ដើម្បីគាំទ្រដល់ផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់
- លើកកម្ពស់ភាពជាពលរដ្ឋក្នុងសង្គម លើកកម្ពស់វប្បធម៌ និងសុខុមាលភាពប្រជាជនសម្រាប់ការត្រៀមខ្លួនជាប្រជាជននៃប្រទេសចំណូលមធ្យមកម្រិតខ្ពស់
- បន្តជំរុញពិពិធកម្មសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍវិស័យដែលជាប្រភពថ្មីនៃកំណើន គាំទ្រដល់បរិយាកាសប្រកួតប្រជែង និងការអនុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគដែលបង្កើនតម្លៃបន្ថែមខ្ពស់

- កសាងជាជំហានៗឆ្ពោះទៅ ការគ្របដណ្តប់សុខភាពជាសកល តាមរយៈការពង្រឹងប្រព័ន្ធសុខាភិបាលជារួម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា និងបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងបន្តអភិវឌ្ឍប្រព័ន្ធស្បៀង ដែលផ្តល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រជាជនគ្រប់រូប
- បន្តជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ ទាំងរឹង និងទន់ ដើម្បីបង្កើនផលិតភាព លើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញពិពិធកម្ម
- បន្តជំរុញការធ្វើបរិវត្តកម្មឌីជីថល ដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង ដើម្បីកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថលប្រកបដោយចីរភាព
- បន្តជំរុញការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់ និង
- បន្តលើកស្ទួយវិស័យឯកជន ដោយគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម សេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈការពង្រឹងការអនុវត្តច្បាប់វិនិយោគថ្មី ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច ជាមួយនឹងភាពប្រកួតប្រជែង និងសមភាព។

**១០**- ដើម្បីសម្រេចបាននូវគោលបំណងសំខាន់ៗ នៃក្របខ័ណ្ឌគោលនយោបាយខាងលើនេះ ក្របខ័ណ្ឌថវិកាឆ្នាំ២០២៥ ត្រូវបានរៀបចំឡើងដោយឈរលើគោលការណ៍ និងអភិក្រម ដូចខាងក្រោម៖

**ទី១-ការគោរពឱ្យបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ ជាពិសេសគាំទ្រដល់ការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវវិធានការគោលនយោបាយគន្លឹះ និងវិធានការកែទម្រង់មុតស្រួចនានាដែលបានដាក់ចេញ** : ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់៦,៣% ដែលជាមូលដ្ឋានមិនអាចខ្វះបាន ដើម្បីបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន និងផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកើនឡើងកាន់តែខ្ពស់ ក៏ដូចជាដើម្បីបង្កើនចំណូលថវិកាជាតិផងដែរ។

**ទី២-ការរក្សាតុល្យភាព និងចីរភាពថវិកា** : ពោលគឺ គ្រោងថវិកាផ្អែកចំណាយផ្អែកលើលទ្ធភាពចំណូល ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេស ដោយមិនប្រើប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ទន្ទឹមនេះ បង្កើនការកៀរគរហិរញ្ញប្បទានពីក្រៅ និងក្នុងប្រទេស ដោយប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះទាំង៥ ដែលបានកំណត់ក្នុង **យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ**។

**ទី៣-ការធានាចីរភាព និងសមិទ្ធកម្មនៃចំណូល** : ដើម្បីសម្រេចបាននូវគោលដៅនៃការប្រមូលចំណូលតាមការកំណត់ ក៏ដូចជាដើម្បីឆ្លើយតបនឹងតម្រូវការចំណាយថវិកាជាតិនៅក្នុងឆ្នាំ២០២៥ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលដែលទទួលបន្ទុកកៀរគរចំណូលមិនមែនសារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធ ចាំបាច់ត្រូវបន្តរក្សាចលនការនៃការខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូលថវិកាឱ្យអស់សក្តានុពល ទន្ទឹមនឹងការបន្តរក្សានូវភាពប្រយ័ត្នប្រយែងដោយមិនបង្កផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជន ការធ្វើធុរកិច្ច ប៉ុន្តែបង្កើនការពង្រឹងអភិបាលកិច្ច និងភាពយុត្តិធម៌ ក្នុងការផ្តល់សេវា និងការប្រមូលពន្ធដារ។

**ទី៤-ការតម្កល់មនុស្ស ជាអាទិភាពទី១** ដោយផ្តោតលើ : (១)-ការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការក្នុងគោលដៅរក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីគ្រប់ថ្នាក់ (២)-ការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន ដោយបន្តពង្រឹងនិងពង្រីកការអនុវត្តប្រព័ន្ធលើកទឹកចិត្ត គាំទ្រសមិទ្ធកម្ម ជាពិសេសផ្តល់ការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ សំដៅបង្កើនផលិតភាពការងារ និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ (៣)-ការលើកកម្ពស់គុណភាពអប់រំ និងគុណភាពសេវាសុខាភិបាល តាមរយៈការដាក់ឱ្យអនុវត្តនូវវិធានការគន្លឹះជាក់ស្តែងនានា សំដៅកសាងភាពធន់រឹងមាំប្រកបដោយចីរភាពនៃវិស័យមូលធនមនុស្ស និងសង្គម (៤)-ការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និង (៥)-ការពង្រឹង និងការលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយគាំពារសង្គម សំដៅលើកកម្ពស់សមធម៌ និងស្ថិរភាពសង្គម។

**ទី៥-ការធ្វើវិចារណកម្មលំដាប់អាទិភាព** តាមរយៈ : (១)-ការផ្តល់អាទិភាពដល់ការធានាប្រក្រតីភាព និងនិរន្តរភាពនៃដំណើរការក្រសួង-ស្ថាប័ន (២)-ការគាំទ្រដល់ការបន្តនិរន្តរភាពក្នុងការអនុវត្តគោលនយោបាយអាទិភាព និងវិធានការគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមជាអាទិភាពក្នុងនីតិកាលទី៧នៃរដ្ឋសភា ដែលបានដាក់ចេញក្នុងឆ្នាំ២០២៤ និងការបន្តគាំទ្រដល់វិធានការគន្លឹះឆ្នាំ២០២៥ (៣)-ការទ្រទ្រង់ការងើបវិញ និងការជំរុញសកម្មភាពសេដ្ឋកិច្ច (៤)-ការបន្តគាំទ្រ ឬបន្ថែមការគាំទ្រដល់កម្មវិធី/សកម្មភាពចាំបាច់ខ្លាំង ដែលមិនខ្វះបាន ឬមិនអាចពន្យាពេលបានរបស់ក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ វិធានការបច្ចេកទេសលម្អិតចំនួន៤ទៀត ត្រូវបានបន្តអនុវត្ត រួមមាន៖ *(១)-តម្រង់ការបែងចែកថវិកាឱ្យបានត្រឹមត្រូវ និងចំគោលដៅ ដោយមិនផ្តល់ថវិកាសម្រាប់មុខចំណាយមិនចាំបាច់ និងចំណាយលែងចាំបាច់ (២)-រឹតបន្តឹងខ្លាំងក្នុងការផ្តល់ថវិកាសម្រាប់មុខចំណាយមិនសូវចាំបាច់ (៣)-បន្តផ្តល់ថវិកាចំពោះមុខចំណាយដែលចាំបាច់សម្រាប់ការអនុវត្តសកម្មភាពអាទិភាព និង (៤)-ហ៊ានចាយបន្ថែមលើមុខចំណាយដែលចាំបាច់ខ្លាំង។*

**ទី៦-ការលើកកម្ពស់ប្រសិទ្ធភាពកម្មវិធី និង/ឬសកម្មភាព** : ដោយបន្តគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ បរិមាណ និងគុណភាព ព្រមទាំងជម្រើសបច្ចេកទេស ក្នុងការអនុវត្តកម្មវិធី និង/ឬសកម្មភាព ក្នុងគោលដៅបន្តលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាបង្កើនគុណភាពនៃការកំណត់សូចនាករគន្លឹះឱ្យបានសមស្រប។

**ទី៧-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត** : ពោលគឺជំរុញ និងលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័ន បញ្ចប់ការរៀបចំ និងបង្កើតអង្គភាពថវិកាស្របតាមគោលការណ៍ និងបទដ្ឋានគតិយុត្តជាធរមាន និងប្រែក្លាយអង្គភាពថវិកាទាំងនោះ ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ដើម្បីអង្គភាពនីមួយៗទទួលបានថវិកាគ្រប់ចំនួន និងទាន់ពេល ប្រកបដោយភាពអាចប៉ាន់ប្រមាណបាន និងតម្លាភាព។

**ទី៨-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា** : ដោយផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពចំណាយមិនមែនបុគ្គលិកដល់ក្រសួង-ស្ថាប័ន ដែលកៀរគរចំណូលដោយការខិតខំធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់។ ទន្ទឹមនេះ ក៏លើកទឹកចិត្ត

ឱ្យក្រសួងស្ថាប័នដែលទទួលបានរង្វាន់ពីការផ្តល់សេវាសាធារណៈ ប្រើប្រាស់ប្រាក់រង្វាន់ប្រកបដោយតម្លាភាព ដោយបែងចែកប្រាក់រង្វាន់ក្នុងទំហំសមស្រប សម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន។

**១១**- ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលនយោបាយខាងលើ ក្របខ័ណ្ឌថវិកាឆ្នាំ២០២៥ ត្រូវបានកំណត់ដូចខាងក្រោម៖

| **សូចនាករថវិកា** | ២០២៣ | | ២០២៤ | ២០២៥ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| I. ចំណូលសរុបថវិកាជាតិ (%ផ.ស.ស.) | *២០,៧៧* | *១៩,៨៧* | *១៦,៩៣* | *១៥,១១* |
| ចំណូលក្នុងប្រទេសថវិកាជាតិ (%ផ.ស.ស.) | *១៦,៥៦* | *១៥,៥០* | *១៦,៥៧* | *១៤,៨១* |
| *- ចំណូលចរន្តថវិកាជាតិ (%ផ.ស.ស.)* | *១៥,៩១* | *១៥,២៧* | *១៦,៣០* | *១៤,៥៣* |
| II. ចំណាយសរុបថវិកាជាតិ (%ផ.ស.ស.) | *២២,១៥* | *២១,១៣* | *១៩,៣៣* | *១៨,១៤* |
| *- ចំណាយចរន្តថវិកាជាតិ (%ផ.ស.ស.)* | *១២,៩៥* | *១៣,០២* | *១៣,៤៨* | *១២,៤៦* |
| អតិរេកចរន្ត (%ផ.ស.ស.) | *២,៩៦* | *២,២៥* | *២,៨២* | *២,០៧* |
| III. ឱនភាពសរុប (%ផ.ស.ស.) | *-៥,៥៩* | *-៥,៦២* | *-២,៤០* | *-៣,០៤* |
| IV. តម្រូវការហិរញ្ញប្បទាន | | | *៣,៥០* | *៤,២០* |
| - ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ | | | *២,៤០* | *៣,០៤* |
| - ការទូទាត់ការខ្ចី | | | *១,១០* | *១,១៦* |
| V. ប្រភពហិរញ្ញប្បទាន | | | *៣,៥០* | *៤,២០* |
| - ហិរញ្ញប្បទានក្រៅប្រទេស | | | *៣,២៧* | *៣,៩៦* |
| - ហិរញ្ញប្បទានក្នុងប្រទេស | | | *០,២៣* | *០,២៤* |

តាមក្របខ័ណ្ឌនេះ ចំណូលសរុបថវិកាជាតិឆ្នាំ២០២៥ ត្រូវបានគ្រោងចំនួន៣១ ៩៩៨ប៊ីលានរៀល ស្មើនឹង១៥,១១% នៃផ.ស.ស. ឬថយចំនួន៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដោយក្នុងនោះ ចំណូលចរន្តថវិកាជាតិ ត្រូវបានគ្រោងស្មើនឹង១៤,៥៣% នៃផ.ស.ស. ឬថយចំនួន២,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

១២- គម្រោងចំណូលថវិកាថ្នាក់ជាតិ មានសមាសធាតុដូចខាងក្រោម៖

| សូចនាករថវិកា | ២០២៣ | | ២០២៤ | ២០២៥ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណូលសរុបថវិកាថ្នាក់ជាតិ(%ផ.ស.ស.) | *១៩,៣០* | *១៨,៤៤* | *១៥,៥៧* | *១៣,៨៩* |
| ចំណូលក្នុងប្រទេសថ្នាក់ជាតិ(%ផ.ស.ស.) | *១៥,០៩* | *១៤,០៨* | *១៥,២១* | *១៣,៥៩* |
| ចំណូលចរន្តថវិកាថ្នាក់ជាតិ(%ផ.ស.ស.) | *១៤,៤៤* | *១៣,៩២* | *១៥,០២* | *១៣,៣២* |
| ចំណូលផ្សេងៗ(%ផ.ស.ស.) | *៤,៨៦* | *៤,៥៣* | *០,៥៥* | *០,៥៦* |
| ក្នុងប្រទេស(%ផ.ស.ស.) | *០,៦៥* | *០,១៦* | *០,១៩* | *០,២៦* |
| ក្រៅប្រទេស(%ផ.ស.ស.) | *៤,២១* | *៤,៣៧* | *០,៣៦* | *០,៣០* |

ថវិកាឆ្នាំ២០២៥ ចំណូលថវិកាថ្នាក់ជាតិត្រូវបានគ្រោងចំនួន២៩ ០៤៦ប៊ីលានរៀល ស្មើនឹង ១៣,៨៩% នៃផ.ស.ស. ឬថយចំនួន៣,៨%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ តាមគោលដៅនេះ៖

**ក-ចំណូលចរន្តថវិកាថ្នាក់ជាតិ** ត្រូវសម្រេចឱ្យបានចំនួន២៧ ៨៦៩ប៊ីលានរៀល ត្រូវជា ១៣,៣២% នៃផ.ស.ស. គឺថយចំនួន៣,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលក្នុងនោះ៖

•ចំណូលសារពើពន្ធ ត្រូវសម្រេចឱ្យបានចំនួន២៤ ១៩៩ប៊ីលានរៀល ត្រូវជា១១,៥៧% នៃ ផ.ស.ស. គឺ ថយ៦,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្នុងនោះ៖

- ចំណូលពន្ធ និងអាករគយ ត្រូវបានគ្រោងចំនួន១០ ១៤៦ប៊ីលានរៀល ត្រូវជា៤,៨៥% នៃផ.ស.ស. គឺថយចំនួន៨,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤
- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន១៤ ០៥៤ប៊ីលានរៀល ត្រូវជា៦,៧២% នៃផ.ស.ស. គឺថយចំនួន៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ ទន្ទឹមនេះ រាជរដ្ឋាភិបាលមិនបាន ដាក់ចេញនូវប្រភេទពន្ធថ្មី ឬបង្កើនអត្រាពន្ធនោះទេ។

•ចំណូលមិនមែនសារពើពន្ធ ត្រូវបានគ្រោងចំនួន៣ ៦៧០ប៊ីលានរៀល ត្រូវជា១,៧៥% នៃ ផ.ស.ស. គឺកើនចំនួន១៩,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្នុងនោះ៖

- ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន៣ ៣៨៤ប៊ីលានរៀល កើនចំនួន២១,៤%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៤
- ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីល្បែងកាស៊ីណូ ល្បែងផ្សងសំណាង និងអាជ្ញាបណ្ណ ត្រូវ បានគ្រោងចំនួន២៨៦ប៊ីលានរៀល ថយចំនួន១,៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

**ខ-ចំណូលផ្សេងៗ** ត្រូវបានគ្រោងចំនួន១ ១៧៦ប៊ីលានរៀល ត្រូវជា០,៥៦% នៃផ.ស.ស. ឬកើនចំនួន១១,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលក្នុងនោះ៖

•ចំណូលផ្សេងៗក្នុងប្រទេស៖ ចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពី សហគ្រាសសាធារណៈរបស់រដ្ឋ ត្រូវបានគ្រោងចំនួន៥៥០ប៊ីលានរៀល ត្រូវជា០,២៦% នៃផ.ស.ស. ឬកើនចំនួន៥១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

•ចំណូលផ្សេងៗក្រៅប្រទេស៖ ត្រូវសម្រេចឱ្យបានចំនួន៦២៦ប៊ីលានរៀល ត្រូវជា០,៣% នៃ ផ.ស.ស. ឬថយចំនួន១០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្នុងនោះ៖

▪ ចំណូលមូលនិធិទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន៦១ប៊ីលានរៀល ត្រូវជា០,០៣% នៃ ផ.ស.ស. ឬថយចំនួន១០,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤

▪ ចំណូលផ្សេងៗដោយហិរញ្ញប្បទានពីក្រៅប្រទេស (ចំណូលមិនឆ្លងកាត់តនាគារជាតិ) ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណង ត្រូវបានគ្រោងចំនួន៥៦៦ប៊ីលានរៀល ត្រូវជា០,២៧% នៃផ.ស.ស. ឬថយចំនួន១០,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

**១៣**- ថវិកាឆ្នាំ២០២៥ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយសរុបថវិកាថ្នាក់ជាតិ ឱ្យស្ថិតក្នុងកម្រិតចំនួន៣៥ ៣៩៨ប៊ីលានរៀល ត្រូវជា១៦,៩២% នៃផ.ស.ស. គឺកើនត្រឹមចំនួន២,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្នុងនោះ មានចំណាយឧបត្ថម្ភធនគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៣៦២ ២៨៣លានរៀល ដូចមានឆ្លុះបញ្ចាំងលម្អិតក្នុង **ឧបសម្ព័ន្ធទី១** និងចំណាយឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគូសរំលេចនៅចំណុច៥.១ (ក្នុងទំព័រទី២៥) នៃសេចក្តីថ្លែងហេតុនេះ។

| **សូចនាករថវិកា** | **២០២៣** | | **២០២៤** | **២០២៥** |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណាយសរុបថវិកាថ្នាក់ជាតិ(%ផ.ស.ស.) | *២០,៦៨* | *១៩,៧០* | *១៧,៩៧* | *១៦,៩២* |
| ចំណាយចរន្តថ្នាក់ជាតិ(%ផ.ស.ស.) | *១១,៧៧* | *១២,០៧* | *១២,៤០* | *១១,៤៣* |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | *៤,៣៧* | *៣,៣៨* | *២,៣៤* | *២,២១* |
| គម្រោងវិនិយោគផ្ទាល់ | *៣,២៣* | *២,៩៧* | *១,៥៦* | *០,៨៩* |
| បដិភាគវិនិយោគ | *០,៤១* | *០,២៥* | *០,៤០* | *០,៣៥* |
| មូលនិធិទ្រទ្រង់ថវិកា | *០,៧២* | *០,១៦* | *០,៣៨* | *០,៩៧* |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | *៣,៤៩* | *៣,៣១* | *៣,២៣* | *៣,២៩* |

ទន្ទឹមនេះ សូមជូន**ឧបសម្ព័ន្ធទី១**៖ ចំណូល-ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជាឯកសារព័ត៌មានបន្ថែម ដោយអនុលោមតាមមាត្រា៦០នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**១៤**- ចំណាយចរន្តថ្នាក់ជាតិ ត្រូវបានកំណត់ឱ្យស្ថិតក្នុងកម្រិតចំនួន២៣ ៩០២ប៊ីលានរៀល ត្រូវជា១១,៤៣% នៃផ.ស.ស. ឬកើនចំនួន០,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលក្នុងនោះ៖

**ក-ចំណាយបន្ទុកបុគ្គលិក** រួមមាន : បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័នសាធារណៈ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ មន្ត្រីជាប់កិច្ចសន្យាត្រូវបានគ្រោងចំនួន១០ ៦១២ប៊ីលានរៀល មានសមាមាត្រស្មើនឹង៤៤,៤%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៥,០៧% នៃផ.ស.ស., ឬកើនចំនួន៣,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ ចំណាយបន្ទុកបុគ្គលិកនេះ ត្រូវបានគ្រោងសម្រាប់ : (១)-ការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីជំនួសអ្នកចូលនិវត្តន៍ក្នុងឆ្នាំ២០២៤ ប៉ុន្តែផែនការក្របខ័ណ្ឌសម្រាប់គ្រប់ក្រសួង-ស្ថាប័ន សម្រាប់ឆ្នាំ២០២៥ នឹងត្រូវ

កំណត់ដោយក្រសួងមុខងារសាធារណៈនៅពេលក្រោយ បន្ទាប់ពីការបញ្ចប់ការវិភាគមុខងារឡើងវិញរបស់គ្រប់ក្រសួង-ស្ថាប័ន និង (២)-ការដំឡើងប្រាក់បំណាច់មុខងារ និងការផ្ទេរការគ្រោងចំណាយបន្ទុកបុគ្គលិកនៃមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន៩៦ ៩៥៦,៤ លានរៀល ដែលជាធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ មកកត់ត្រានៅក្នុងវិស័យអប់រំ យុវជន និងកីឡាវិញ។ ក្នុងស្មារតីបន្តអនុវត្តគោលនយោបាយដំឡើងបៀវត្សជូនមន្ត្រីរាជការ សំដៅរក្សាលំនឹង និងលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងមន្ត្រីផ្សេងទៀត ការដំឡើងបៀវត្សសម្រាប់ឆ្នាំ២០២៥ ត្រូវបានគិតគូរទៅតាមលទ្ធភាពថវិកាក្នុងរង្វង់៣% ដែលកំណើននេះលើសពីអត្រាអតិផរណាដែលបានប៉ាន់ស្មានត្រឹម២,៥%។ ការដំឡើងបៀវត្សនេះ ត្រូវបានគិតគូរតាមអភិក្រមដំឡើងលើប្រាក់បំណាច់មុខងារចំនួន៤០ ០០០រៀលជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយគិតអនុវត្តសម្រាប់រយៈពេល១២ខែ គឺពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥។ ជាលទ្ធផល បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ មានដូចខាងក្រោម៖

- បៀវត្សមន្ត្រីរាជការស៊ីវិលទូទៅ នឹងត្រូវបានដំឡើងពីចំនួន១ ៣៥៦ ៩៥០រៀល នៅឆ្នាំ២០២៤ ដល់ប្រមាណ១ ៣៩៦ ៩៥០រៀល នៅឆ្នាំ២០២៥
- បៀវត្សគ្រូបង្រៀន និងគ្រូពេទ្យ នឹងត្រូវបានដំឡើងពីចំនួន១ ៤៥៦ ៩៥០រៀល នៅឆ្នាំ២០២៤ ដល់ប្រមាណ១ ៤៩៦ ៩៥០រៀល នៅឆ្នាំ២០២៥
- បៀវត្សនគរបាលជាតិ (ពលបាលត្រី) នឹងត្រូវបានដំឡើងពី១ ៤៤៣ ៩២៧រៀល (ដោយគិតបញ្ចូលទាំងរបបអង្ករ) នៅឆ្នាំ២០២៤ ដល់ប្រមាណ១ ៤៨៣ ៩២៧រៀល (ដោយគិតបញ្ចូលទាំងរបបអង្ករ) នៅឆ្នាំ២០២៥
- បៀវត្សយោធិន (ពលទោ) នឹងត្រូវបានដំឡើងពី១ ៣០៦ ៥៥០រៀល (ដោយមិនទាន់គិតបញ្ចូលរបបអង្ករ) នៅឆ្នាំ២០២៤ ដល់ប្រមាណ១ ៣៤៦ ៥៥០រៀល (ដោយមិនទាន់គិតបញ្ចូលរបបអង្ករ) ហើយបើគិតបញ្ចូលទាំងរបបអង្ករ ត្រូវជាប្រមាណ១ ៤០៥ ០២៧ រៀល នៅឆ្នាំ២០២៥។

ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា នឹងត្រូវបានដំឡើងពី៧៧ម៉ឺនរៀល ទៅដល់៧៩ម៉ឺនរៀល ដោយគិតអនុវត្តចាប់ពីខែមករា ឆ្នាំ២០២៥។

ទន្ទឹមនេះដែរ ប្រាក់សោធនប្រចាំខែរបស់និវត្តជន ជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន រួមទាំងជនបាត់បង់សមត្ថភាពការងារ និងជនពិការត្រូវបានដំឡើងជាបន្តបន្ទាប់ ដោយផ្តោតការយកចិត្តទុកដាក់លើប្រាក់សោធនអប្បបរមា និងលើការបន្ថយគម្លាតរវាងប្រាក់សោធនអប្បបរមា និងអតិបរមា។ ជាក់ស្តែង ជាលទ្ធផលនៃការបញ្ចប់ការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាលអំពីការធ្វើសមាហរណកម្មប្រាក់សោធនតាមប្រព័ន្ធបៀវត្សចាស់ ចូលទៅក្នុងប្រព័ន្ធបៀវត្សថ្មី ក្នុងរយៈពេល២ឆ្នាំ (២០២៣-២០២៤) ដើម្បីដោះស្រាយបញ្ហាគម្លាតរវាង អ្នកចូលនិវត្តចាស់និងថ្មី ប្រាក់សោធនអប្បបរមាប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន (អតីតយោធិន និងអតីតមន្ត្រីនគរបាលជាតិ) ត្រូវបានដំឡើងដល់៧៧ម៉ឺនរៀល នៅឆ្នាំ២០២៣ និងឡើងដល់៨២,៥ម៉ឺនរៀល នៅឆ្នាំ២០២៤។ សម្រាប់ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន១០០ប៊ីលានរៀល សម្រាប់ការបន្តដំឡើង

ប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។

លើសពីនេះ សម្រាប់ឆ្នាំ២០២៥នេះដែរ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន១២០ប៊ីលានរៀល សមមូលនឹងប្រមាណ៣០លានដុល្លារអាម៉េរិក ដោយឡែកផ្សេងទៀត សម្រាប់ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ដោយផ្តោតជាសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្ម របស់មន្ត្រី និងស្ថាប័ន តាមរយៈការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ហើយកិច្ចការនេះនឹងត្រូវបន្តដាក់អនុវត្តក្រោមការដឹកនាំដោយផ្ទាល់ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន៧៩,២ប៊ីលានរៀល (ជាចំណាយមិនមែនបន្ទុកបុគ្គលិក) សម្រាប់ការថែទាំសុខភាពមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន ព្រមទាំងបានបន្តគ្រោងថវិកាចំនួន៦ប៊ីលានរៀល សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ ដើម្បីលើកកម្ពស់សុខភាពមន្ត្រីរាជការ។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន១៣ ២៩០ប៊ីលានរៀល មានសមាមាត្រស្មើនឹង៥៥,៦%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៦,៣៥% នៃផ.ស.ស. ឬថយចំនួន១,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ ការណ៍នេះបង្ហាញថា ថវិកាឆ្នាំ២០២៥ បានរងនូវសម្ពាធខ្លាំង ដោយសារអតុល្យភាពរវាងលទ្ធភាពនៃចំណូល និងតម្រូវការចំណាយដែលប្រឈមនឹងសម្ពាធកាន់តែធំនៃតម្រូវការជាកាតព្វកិច្ចនានារបស់ក្រសួង-ស្ថាប័ន ដែលត្រូវការថវិកាជាចាំបាច់ក្នុងការអនុវត្តសកម្មភាពអាទិភាពរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលដៅសូចនាករពាក់ព័ន្ធនឹងសមត្ថកិច្ចខ្លួន ដែលមានចែងក្នុងកម្មវិធី និងគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ ជាពិសេសយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ ក្នុងស្ថានភាពនេះ ស្របតាមស្មារតីនៃការពង្រឹងប្រសិទ្ធភាពវិភាជថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានខិតខំជួយតម្រង់ការវិភាជថវិកាទៅតាមក្រសួង-ស្ថាប័នឱ្យបានត្រឹមត្រូវ និងចំគោលដៅ ហើយត្បិតត្បៀតលើមុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ក៏ដូចជាបញ្ចប់ការគ្រោងថវិកាសម្រាប់មុខចំណាយដែលលែងចាំបាច់ ព្រមទាំងកែសម្រួលគម្រោងចំណាយមួយចំនួន ដើម្បីរក្សាលម្ហថវិកាចំណាយមិនមែនបន្ទុកបុគ្គលិកសម្រាប់បង្កើនលើមុខសញ្ញាចំណាយថ្មី ឬសកម្មភាពថ្មី ដែលបម្រើឱ្យការអនុវត្តកម្មវិធីកែទម្រង់ថ្មីៗ និងគោលនយោបាយអាទិភាពរបស់ក្រសួង-ស្ថាប័ន។ ដូចនេះ ជារួម ទំហំចំណាយមិនមែនបន្ទុកបុគ្គលិកឆ្នាំ២០២៥ ត្រូវបានរក្សាក្នុងកម្រិតទំហំថវិកាដែលកំណត់ក្នុងក្របខ័ណ្ឌថវិកា។

**១៥**- ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានវិភាជន៍តាមវិស័យ ហើយនៅកម្រិតក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានធ្វើការវិភាជបន្តទៅតាមកម្មវិធី អនុកម្មវិធី រហូតដល់ចង្កោមសកម្មភាព ព្រមទាំងឆ្លុះបញ្ចាំងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា ដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់ ដូចតទៅ៖

១-ចំណាយចរន្តវិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងថវិកាចំនួន៣ ២៤០ប៊ីលានរៀល, ត្រូវជា ១,៥៥% នៃផ.ស.ស. កើនចំនួន៨,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលមូលហេតុសំខាន់បំផុតនៃការកើននៃវិស័យនេះគឺ ដោយសារការគ្រោងចំណាយលើការចុះបញ្ជីដីធ្លីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធចំនួន១៣៨ប៊ីលានរៀល ដែលប្រើប្រកពចំណូលពីការបង់កម្រៃសេវារបស់ម្ចាស់ដី

(លើកលែងប្រជាពលរដ្ឋក្រីក្រនិងងាយរងគ្រោះ) ដើម្បីអនុវត្តយុទ្ធនាការចុះបញ្ជីបង្កើយ ក្នុងរយៈពេលពី ២ទៅ៤ឆ្នាំ។ អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្តោតទៅលើកម្មវិធី និងសកម្មភាពការងារ មានជាអាទិ៍៖

- ការគាំទ្រព្រះរាជសកម្មភាពរបស់ព្រះករុណាព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី វររាជមាតាជាតិខ្មែរ
- ការបន្តអនុវត្តការងារ និងតួនាទីនីតិប្បញ្ញត្តិរបស់រដ្ឋសភា និងព្រឹទ្ធសភា និងបន្តគាំទ្រដល់កិច្ចដំណើរការរបស់ដល់អគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា
- ការគាំទ្រដល់ការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ការបន្តគាំទ្រដល់ការពង្រឹង និងការពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្រៅប្រទេស និងការងារការទូតសេដ្ឋកិច្ច ដើម្បីបន្តលើកកម្ពស់តួនាទីរបស់កម្ពុជា ក្នុងកិច្ចការតំបន់ និងនៅលើឆាកអន្តរជាតិ ដោយស្មើសិទ្ធិ និងស្មើភាព ព្រមទាំងបន្តផ្តល់ការគាំទ្រដល់កិច្ចការពារ និងជួយសង្គ្រោះពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស ពិសេស ស្ត្រីខ្មែរដែលត្រូវរងគ្រោះដោយការឆបោក និងការជួញដូរផ្លូវភេទ
- ការគាំទ្រដល់ការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រួមទាំង ការអនុវត្តការងារពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការគាំទ្រដល់ការងារសម្របសម្រួលលើកិច្ចការទូទៅរបស់គណៈរដ្ឋមន្ត្រី និងការងាររបស់អង្គភាពពាក់ព័ន្ធផ្សេងដែលស្ថិតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី រួមទាំង ការគាំទ្រដល់ការងារកែទម្រង់ច្បាប់ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ព្រមទាំងការគាំទ្រដល់ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១
- ការបន្តគាំទ្រដល់ការងារកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសការពង្រឹងសមត្ថភាពស្ថាប័ន និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ
- ការបន្តគាំទ្រដល់ការងារទាក់ទាញនិងការគ្រប់គ្រងវិនិយោគឯកជន និងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍
- ការបន្តការធ្វើទំនើបកម្ម និងប្រព័ន្ធស្វ័យប្រវត្តិកម្មរដ្ឋបាលសារពើពន្ធ ដើម្បីគាំទ្រដល់កិច្ចសម្រួលពាណិជ្ជកម្ម ការធ្វើធុរកិច្ច ការកៀរគរ និងការគ្រប់គ្រងចំណូល
- ការបន្តការធ្វើទំនើបកម្មការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដើម្បីបង្កើនប្រសិទ្ធភាពនៃការរៀបចំ ការវិភាជន៍ និងការអនុវត្តថវិកា
- ការគាំទ្រដល់ការងាររៀបចំ អនុវត្ត និងត្រួតពិនិត្យ គោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច រួមទាំងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ច និងសង្គមឌីជីថល
- ការគាំទ្រដល់ការអនុវត្តគម្រោងអភិវឌ្ឍ និងប្រតិបត្តិថ្នាលចុះឈ្មោះប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាផ្នែកមួយការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ការបន្តគាំទ្រដល់មូលនិធិអភិវឌ្ឍន៍ជំនាញ
- ការបន្តចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ទាំងដីឯកជន ដីរដ្ឋ និងដីសហគមន៍

- ការបន្តការដោះស្រាយទំនាស់ដីធ្លី និងការបែងចែកដីសម្បទានសង្គមកិច្ច
- ការគាំទ្រដល់ការពង្រឹងការគ្រប់គ្រងវិស័យសំណង់ ការរៀបចំប្លង់គោល និងនគរូបនីយកម្ម
- ការបន្តការអនុវត្តតួនាទីសវនកម្ម លើការប្រើប្រាស់ធនធានសាធារណៈ
- ការបន្តគាំទ្រដល់ការធ្វើអធិការកិច្ច និងការងារដោះស្រាយបណ្ដឹង
- ការគាំទ្រដល់ការអភិវឌ្ឍ ការពង្រឹង និងពង្រីកប្រព័ន្ធស្ថិតិជាតិ
- ការបន្តគាំទ្រដល់សកម្មភាពបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ
- ការបន្តគាំទ្រដល់ការបញ្ជូនកងកម្លាំងកម្ពុជាទៅចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពនៅក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ
- ការបន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និង
- ការបន្តគាំទ្រដល់វេទិកាសម្ព័ន្ធសង្គមស៊ីវិល ដើម្បីពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ក្នុងកិច្ចអភិវឌ្ឍប្រទេស និងការលើកស្ទួយសិទ្ធិមនុស្ស។

២-ចំណាយចរន្តវិស័យការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងថវិកាចំនួន៥ ៦២៥ប៊ីលានរៀល ត្រូវជា២,៦៩% នៃផ.ស.ស. ឬកើនចំនួន៣,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ **អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្ដោតទៅលើកម្មវិធី និងសកម្មភាពការងារ មានជាអាទិ៍៖**

- ការបន្តផ្ដោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធរួមទាំងការហ្វឹកហ្វឺន និងការថែទាំ និងជួសជុលគ្រឿងចក្រយុទ្ធោបករណ៍
- ការបន្តគាំទ្រដល់ការអនុវត្តកិច្ចការពារអធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាព និងកិច្ចប្រតិបត្តិការសង្គ្រោះប្រជាពលរដ្ឋ ពេលមានគ្រោះមហន្តរាយផ្សេងៗ
- ការបន្តគាំទ្រដល់ការអនុវត្តកិច្ចការសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងគ្រឿងញៀន ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្ត្រី និងកុមារ ព្រមទាំងការប្រយុទ្ធប្រឆាំងទារុណកម្ម អំពើឃោរឃៅ និងអមនុស្សធម៌
- ការបន្តគាំទ្រដល់ការផលិតលិខិតឆ្លងដែន និងប្រតិបត្តិការផលិតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋ ព្រមទាំងការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន
- ការបន្តពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព"
- ការបន្តការគាំទ្រដល់ការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនដល់កងកម្លាំងនគរបាលជាតិ
- ការបន្តការគាំទ្រដល់កិច្ចដំណើរការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ការពង្រឹងការគ្រប់គ្រង និងការផ្ដល់សេវាសាធារណៈ នៅរដ្ឋបាលមូលដ្ឋាន
- ការគាំទ្រដល់ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ តាមរយៈការអនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ព្រមទាំងការអនុវត្តយន្តការសម្រាប់ជំរុញ និងពន្លឿនការដោះស្រាយរឿងក្ដីនៅតាមតុលាការឱ្យបានឆាប់រហ័ស និងការត្រួតពិនិត្យ និងការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ

- ការបន្តគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ ដើម្បីលើកកម្ពស់សេវាយុត្តិធម៌ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា ព្រមទាំងការបន្តគាំទ្រដល់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- ការបន្តគាំទ្រដល់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងក្តីនៅតាមសាលាជម្រះក្តី និងការពង្រឹងការគ្រប់គ្រងទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី
- ការគាំទ្រដល់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ជាពិសេស ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងសាការី
- ការបន្តផ្តល់ថវិកាការពារក្តីជូនគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សេវាការពារក្តីដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ និង
- ការបន្តគាំទ្រសកម្មភាពការងារពាក់ព័ន្ធនឹងកិច្ចការព្រំដែន ការចុះវាស់វែង ថែទាំ និងបោះបង្គោលព្រំដែន។

៣-ចំណាយចរន្តវិស័យសង្គមកិច្ច ត្រូវបានគ្រោងថវិកាចំនួន៩ ៤៣៣ប៊ីលានរៀល ត្រូវជា៤,៩១% នៃផ.ស.ស. ឬកើនចំនួន២,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ពោលគឺវិស័យនេះ នៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី១ នៅក្នុងការរៀបចំថវិកាជាតិឆ្នាំ២០២៥។ អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្តោតទៅលើ **ការអភិវឌ្ឍមូលធនមនុស្ស** ដែលត្រូវបានចាត់ទុកថាជា **អាទិភាពទី១** នៅក្នុងចំណោមអាទិភាពគន្លឹះទាំង៥ របស់រាជរដ្ឋាភិបាល តាមរយៈការផ្តល់ការគាំទ្រដល់កម្មវិធី និងសកម្មភាពការងារ មានជាអាទិ៍៖

ទី១-ការលើកកម្ពស់គុណភាពអប់រំ និងការបន្តគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ ព្រមទាំងការអប់រំកាយនិងកីឡា តាមរយៈ៖

- ការផ្តល់អាហារូបករណ៍ដល់គរុសិស្ស និងនិស្សិត ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូ បង្រៀន
- ការបន្តបង្កើនថវិកាដំណើរការសាលារៀន មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្ត និងសាលាគរុកោសល្យនិងវិក្រឹត្យការខេត្ត ដើម្បីលើកកម្ពស់សេវាអប់រំតាមសាលារៀន
- ការគាំទ្រដល់ការកែទម្រង់កម្មវិធីសិក្សា និងការបោះពុម្ពសៀវភៅសិក្សាគោល ព្រមទាំងបែងចែក និងបញ្ជូនឱ្យទាន់ពេល និងស្របតាមមុខវិជ្ជាដែលសាលារៀននីមួយៗមានតម្រូវការជាក់ស្តែង
- ការបន្តបង្កើនការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន គ្របដណ្តប់លើសាលារៀនគោលដៅចំនួន៦៨៦ ក្នុងខេត្តចំនួន១០ និងមានសិស្សទទួលអាហារចំនួនជាង១៩ម៉ឺននាក់
- ការបន្តផ្តល់អាហារូបករណ៍ប្រចាំឆ្នាំដល់សិស្សក្រីក្រនៅគ្រប់កម្រិត ដើម្បីជួយកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស និងសម្រាលបន្ទុកចំណាយរបស់មាតាបិតា និងអាណាព្យាបាលសិស្ស ពិសេសដើម្បីផ្តល់ឱកាសដល់សិស្សក្រីក្រឱ្យទទួលបាននូវការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន តាមរយៈយន្តការកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

- ការបន្តសាងសង់បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាតនៅតាមសាលារៀន ដើម្បីផ្ដល់ភាពងាយស្រួលដល់ការរៀនសូត្ររបស់កុមារី និងយុវតី ក៏ដូចជាសុខុមាលភាពសិស្សជាទូទៅ
- ការគាំទ្រដល់ការលើកកម្ពស់អនាម័យសាលារៀននៅរាជធានីភ្នំពេញ តាមរយៈការបន្ថែមថវិកាសម្រាប់បង់ថ្លៃសេវាប្រមូលសំរាមពីគ្រប់សាលារៀននៅក្នុងរាជធានីភ្នំពេញ
- ការបន្តពង្រឹង និងពង្រីកសាលារៀនជំនាន់ថ្មី នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ព្រមទាំងវិទ្យាល័យ ចំណេះទូទៅ និងបច្ចេកទេស
- ការអភិវឌ្ឍជំនាញទន់ដល់យុវជន តាមរយៈការគាំទ្រការអនុវត្តកម្មវិធី "មនសិការពលរដ្ឋល្អ" ដើម្បីកសាង និងអភិវឌ្ឍធនធានយុវជនកម្ពុជាប្រកបដោយសមត្ថភាព បំណិនជីវិត គំនិតច្នៃប្រឌិត មានមនសិការស្នេហាជាតិ និងភាពជាពលរដ្ឋល្អ
- ការគាំទ្រការពង្រីកការអនុវត្តស្តង់ដាសាលារៀនគំរូ និងការគាំទ្រដល់លេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ (គ.វ.អ.)
- ការបន្តលើកកម្ពស់គុណភាពឧត្តមសិក្សា ពិសេសការគាំទ្រដល់ការសិក្សា និងស្រាវជ្រាវលើមុខជំនាញវិទ្យាសាស្ត្រពិត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និងការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ
- ការបន្តលើកកម្ពស់ការអប់រំកាយ និងកីឡា ជាពិសេសការផ្តល់ការហ្វឹកហាត់ ដើម្បីត្រៀមចូលរួមការប្រកួតកីឡាលក្ខណៈតំបន់ និងអន្តរជាតិ
- ការបន្តកសាងអគារសិក្សា និងការជួសជុលថែទាំអគារសិក្សា រួមទាំងការបំពាក់តុកៅអី តាមសាលារៀន។

**ទី២- ការបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការអភិវឌ្ឍវិស័យការងារ និងការរក្សាសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈមានជាអាទិ៍៖**

- ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈគ្រប់កម្រិត **ដោយផ្តល់អាទិភាពជាពិសេសលើការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**កម្រិតទី១ ដោយផ្តល់អាហារូបករណ៍ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស ដើម្បីជួយពួកគេឱ្យបានចូលទីផ្សារការងារបានឆាប់
- ការពង្រឹង និងការជំរុញការងារប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈពីចម្ងាយឬតាមអនឡាញ និងប្រព័ន្ធជាតិវាយតម្លៃទទួលស្គាល់ការសិក្សាពីមុនពីចម្ងាយសម្រាប់ការវាយតម្លៃផ្អែកលើសមត្ថភាព និងផ្តល់គុណវុឌ្ឍិជាតិកម្ពុជា
- ការបន្តអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល និងកញ្ចប់សិក្សាផ្អែកលើសមត្ថភាព ព្រមទាំងការពង្រឹងសមត្ថភាព និងគុណភាពគ្រូបច្ចេកទេស
- ការបន្តគាំទ្រដល់ការពង្រីកនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ពិសេសគ្រឹះស្ថានដែលទទួលបានវិញ្ញាបនបត្រអង្គការស្តង់ដាអន្តរជាតិ ដោយរួមទាំងការបន្តបំពាក់សម្ភារៈបរិក្ខារ ឧបករណ៍ពិសោធន៍ថ្មីៗ

ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្មឱ្យមានជំនាញច្បាស់លាស់ និងលើកកម្ពស់ផលិតភាពអាចឆ្លើយតបតម្រូវការទីផ្សារការងារទាំងបរិមាណ និងគុណភាព

- ការបន្តគាំទ្រតួនាទីរបស់ទីភ្នាក់ងារជាតិមុខរបរនិងការងារ ក្នុងការផ្តល់សេវាស្វែងរកការងារធ្វើជូនយុវជន ទាំងនៅក្នុងនិងក្រៅប្រទេស
- ការគាំទ្រដល់ការពង្រឹងការគ្រប់គ្រងពលករអន្តោប្រវេសន៍ និងការអនុវត្តច្បាប់ការងារឱ្យមានប្រសិទ្ធភាពខ្ពស់ និងការបន្តគាំទ្រដល់ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ
- ការពង្រឹងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការពង្រឹងយន្តការបង្ការទប់ស្កាត់និងដោះស្រាយវិវាទការងារនៅគ្រប់ដំណាក់កាល យុទ្ធនាការលើកកម្ពស់សិទ្ធិការងារ និងសំវាទសង្គម និងការគ្រប់គ្រងហានិភ័យវិវាទ ការពង្រឹងយន្តការត្រីភាគី និងកិច្ចសន្ទនាសង្គម ព្រមទាំងជំរុញយុទ្ធនាការថ្នាក់ជាតិស្តីពីសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ និងការពង្រឹងយន្តការបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញាជាដើម។

ទី៣- ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសកល ពិសេសសម្រាប់ប្រជាជនក្រីក្រ ក្រុមជនងាយរងគ្រោះ ស្ត្រី និងកុមារ តាមរយៈ៖

- ការបន្តគាំទ្រ និងបង្កើនថវិកា សម្រាប់ទ្រទ្រង់ប្រតិបត្តិការមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពទូទាំងប្រទេស ដោយផ្ទេរថវិកាទៅដល់អ្នកអនុវត្តផ្ទាល់សម្រាប់គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល និងពង្រឹងការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល ឆ្នាំ២០២៤-២០២៧ ដែលក្នុងនោះ៖
    - បង្កើនថវិកាពីចំនួន៥៥០លានរៀល ទៅ៦១០លានរៀល ដល់មន្ទីរពេទ្យបង្អែក កម្រិត៣ ទូទាំងប្រទេស ដែលសរុបមាន២២មន្ទីរពេទ្យ
    - បង្កើនថវិកាពីចំនួន៥០០លានរៀល ទៅ៥៧០លានរៀល ដល់មន្ទីរពេទ្យបង្អែក កម្រិត២ ទូទាំងប្រទេស ដែលសរុបមាន៣៨មន្ទីរពេទ្យ
    - បង្កើនថវិកាពីចំនួន៤៥០លានរៀល ទៅ៥៣០លានរៀល ដល់មន្ទីរពេទ្យបង្អែក កម្រិត១ ទូទាំងប្រទេស ដែលសរុបមាន៦៧មន្ទីរពេទ្យ
    - បង្កើនថវិកាពីចំនួន៣៥លានរៀល ទៅ៤៥លានរៀល ដល់មណ្ឌលសុខភាព ដែលគ្របដណ្តប់ប្រជាជនច្រើនជាង១ម៉ឺននាក់ ដែលសរុបមាន៥១៤មណ្ឌលសុខភាព
    - បង្កើនថវិកាពីចំនួន១៩លានរៀល ទៅ២៩លានរៀល ដល់មណ្ឌលសុខភាព ដែលគ្របដណ្តប់ប្រជាជនតិចជាង១ម៉ឺននាក់ ដែលសរុបមាន៤១៦មណ្ឌលសុខភាព
    - បង្កើនថវិកាពីចំនួន៨លានរៀល ទៅ១០លានរៀល ដល់ប៉ុស្តិ៍សុខភាពទូទាំងប្រទេស ដែលសរុបមាន១១៩ប៉ុស្តិ៍សុខភាព។

- ការបន្តការផ្តល់ថវិកា សម្រាប់គាំទ្រដល់មូលនិធិមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា ដើម្បីធានាបានថា មន្ទីរពេទ្យនេះនៅតែអាចរក្សាបាននូវស្តង់ដាគុណភាព និងការផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃដដែល
- ការបន្តបង្កើនថវិកាគាំទ្រដល់កម្មវិធីមូលនិធិសមធម៌សុខាភិបាល ដើម្បីផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃជូនដល់ប្រជាជនក្រីក្រ ប្រជាពលរដ្ឋងាយរងហានិភ័យ និងកម្មករនិយោជិតក្រៅប្រព័ន្ធដែលមិនស្ថិតក្រោមបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៅទូទាំងប្រទេស
- ការបន្តពង្រឹងនិងពង្រីកការគ្របដណ្តប់ជាសកលសម្រាប់ការឧបត្ថម្ភមាតុភាព ទាំងក្នុងពេលមានផ្ទៃពោះពេលសម្រាល និងទាំងក្រោយពេលសម្រាល ជូនដល់កម្មករនិយោជិក មន្ត្រីរាជការ មន្ត្រីកម្មសិក្សា មន្ត្រីជាប់កិច្ចសន្យា និងស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- ការបន្តគាំទ្រដល់ការថែទាំសុខភាពមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងអ្នកនៅក្នុងបន្ទុក និងនិវត្តជន ព្រមទាំង របបសន្តិសុខសង្គមផ្នែកហានិភ័យការងារចំពោះមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន
- ការបន្តបង្កើនថវិកាសម្រាប់ការផ្គត់ផ្គង់ឱសថ វ៉ាក់សាំង ប្រតិករ និងបរិក្ខាពេទ្យដល់មន្ទីរពេទ្យ រួមទាំងការបង្កើនការឧបត្ថម្ភធនកាន់តែច្រើនដល់មន្ទីរពេទ្យនៅថ្នាក់ជាតិ វិទ្យាស្ថាន និងមន្ទីរពិសោធន៍ ដើម្បីពង្រីក និងពង្រឹងការផ្តល់សេវាសុខាភិបាល និងការត្រៀមប្រយុទ្ធប្រឆាំងទប់ទល់នឹងវិបត្តិនៃជំងឺឆ្លងសកល ជាយថាហេតុ។

ទី៤- ការបន្តគាំទ្រដល់ការអនុវត្តកម្មវិធីជំនួយសង្គម រួមមាន៖

- ការគាំទ្រដល់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដូចជា កម្មវិធីឧបត្ថម្ភគោលសម្រាប់គ្រួសារក្រីក្រទាំងអស់ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ៦០ឆ្នាំឡើង) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព និងកម្មវិធីឧបត្ថម្ភជូនអ្នកផ្ទុកមេរោគអេដស៍ ការផ្តល់អាហារូបករណ៍ដល់សិស្សក្នុងបន្ទុកគ្រួសារ
- ការគាំទ្រដល់កម្មវិធីស្តារជីវភាពឡើងវិញសម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែងនៃស្រុកអង្គរធំ ខេត្តសៀមរាប។

ទី៥- អាទិភាពផ្សេងទៀត ក្នុងវិស័យសង្គមកិច្ច រួមមាន៖

- ការបន្តផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន
- ការបន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន ការបន្តផ្តល់សេវាជូនជនពិការ និងការពង្រីកសកម្មភាពជួយជនពិការក្រីក្រ ចាស់ជរា នៅតាមសហគមន៍
- ការបន្តឧបត្ថម្ភគោលនយោបាយជូនជនរងគ្រោះ ដោយសារការប្រើប្រាស់គ្រឿងញៀន និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ការបន្តឧបត្ថម្ភគោលនយោបាយជូនជនវិបល្លាសស្មារតី ជនចំណាកស្រុក ជនអនាថា និងអនីតិជនដែលទំនាស់នឹងច្បាប់ ជាដើម

- ការបន្តគាំទ្រដល់កិច្ចគាំពារបរិស្ថាននិងការងារអភិរក្ស ដូចជាប្រតិបត្តិការល្បាតរបស់ឧទ្យានុរក្ស ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការតាមដានគុណភាពខ្យល់ ព្រមទាំងការលើកកម្ពស់ជីវភាពសហគមន៍តំបន់អភិរក្សធម្មជាតិ
- ការបន្តគាំទ្រដល់ការលើកកម្ពស់យេនឌ័រ និងគណៈកម្មាធិការសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ព្រមទាំងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីផ្តល់សេវាផ្នែកច្បាប់ចំពោះស្ត្រីក្រីក្រងគ្រោះ ដោយអំពើហិង្សាគ្រប់ទម្រង់
- ការបន្តគាំទ្រដល់ការពង្រឹង និងពង្រីកការគ្រប់គ្រង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីធានាឱ្យបាននូវការផ្សាយព័ត៌មានប្រកបដោយគុណភាព តាមក្រមសីលធម៌វិជ្ជាជីវៈ
- ការបន្តគាំទ្រដល់ការអភិរក្ស និងអភិវឌ្ឍសម្បត្តិបេតិកភណ្ឌជាតិ ការសិក្សា និងចងក្រងសម្បត្តិវប្បធម៌អរូបីយនានា ពិសេសការគាំទ្រដល់ការបណ្តុះបណ្តាលសិល្បៈបុរាណជំនាញ និងការបន្តជួសជុលប្រាសាទបុរាណដែលជិតដួលរលំ
- ការបន្តគាំទ្រដល់ការបណ្តុះបណ្តាលជំនាញជូនតា ដោយមានផ្តល់អាហារូបករណ៍ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស និង
- ការបន្តលើកស្ទួយសុខដុមនីយកម្មសាសនានៅកម្ពុជា ពិសេសការបន្តគាំទ្រដល់ពុទ្ធិកសិក្សានៅគ្រប់កម្រិត និងការផ្សព្វផ្សាយព្រះពុទ្ធសាសនា ។

ទន្ទឹមនេះ ក្រៅពីថវិកាចំណាយចរន្តដែលត្រូវបានវិភាជជូនក្រសួង ស្ថាប័ន សម្រាប់អនុវត្តកម្មវិធី និងសកម្មភាពការងារអាទិភាពដូចបានជម្រាបជូនខាងលើ ក្រសួង ស្ថាប័នមួយចំនួនក្នុងវិស័យសង្គមកិច្ច ក៏ទទួលបានផងដែរនូវថវិកាគម្រោងវិនិយោគផ្ទាល់ ដូចមានឆ្លុះបញ្ចាំងក្នុង **ឧបសម្ព័ន្ធទី២**។

៤-ចំណាយចរន្តវិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងថវិកាចំនួន១ ៨៣៨ប៊ីលានរៀល, ត្រូវជា០,៨៨% នៃផ.ស.ស. ឬកើនចំនួន៤,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ គួរកត់សម្គាល់ថា ទោះបីជាក្រសួងសំខាន់ៗនៅក្នុងវិស័យសេដ្ឋកិច្ចនេះ មិនបានទទួលនូវកំណើនចំណាយចរន្តថវិកាថ្នាក់ជាតិច្រើន និងនៅមានទំហំតូចក្តី តែក្រសួងសំខាន់ៗទាំងនេះបានស្រូបយកចំណាយវិនិយោគផ្ទាល់ ដោយហិរញ្ញប្បទានក្នុងប្រទេស ក៏ដូចជាគម្រោងហិរញ្ញប្បទានពីក្រៅប្រទេសក្នុងទំហំធំ។

**អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្តោតទៅលើកម្មវិធី និងសកម្មភាពការងារ មានជាអាទិ៍៖**

- ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្ម ទៅគ្រប់ឃុំ-សង្កាត់ ទូនៅទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងជួយដល់គ្រួសារកសិករ ក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន និងការរៀបចំឱ្យមានសមាគមកសិកម្មនៅតាមទីជនបទ
- ការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ ពិសេសការផលិតគ្រាប់ពូជស្រូវ និងផលិតកម្មបន្លែ ព្រមទាំងការជំរុញខ្សែច្រវាក់ផលិតកម្មដំណាំ ដូចជា បន្លែសុវត្ថិភាព ម្រេច និងដំណាំស្វាយ ជាដើម ដើម្បីជំរុញការធ្វើពិពិធកាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម
- ការជំរុញផលិតកម្មកៅស៊ូប្រកបដោយគុណភាព និងការពង្រឹងយន្តការទីផ្សារកៅស៊ូ

- ការជំរុញការចិញ្ចឹមសត្វតាមបច្ចេកទេស និងការទប់ស្កាត់ជំងឺឆ្លងសត្វ ព្រមទាំងការផ្គត់ផ្គង់វ៉ាក់សាំង និងបសុឱសថ សម្រាប់ចាក់ការពារនិងព្យាបាលគោ ក្របី ជូនប្រជាកសិករ ដើម្បីបង្កើនសុវត្ថិភាពផលិតកម្មសត្វ
- ការគ្រប់គ្រងសហគមន៍ អភិរក្ស និងការគ្រប់គ្រងដែននេសាទ ព្រមទាំងការបង្ក្រាបបទល្មើសនេសាទ ជាពិសេសក្នុងតំបន់ទន្លេសាប និងសមុទ្រ
- ការជំរុញការអភិវឌ្ឍចម្ការឈើដាំនិងរុក្ខវប្បកម្ម និងលើកកម្ពស់ការងារដាំឈើ សំដៅបង្កើនគម្របព្រៃឈើនៅលើផ្ទៃដីរិចរិល និងបង្កើនទិន្នផលឈើដាំ
- ការបង្ក្រាបបទល្មើសព្រៃឈើ និងការស្តារព្រៃឈើឡើងវិញ និងពង្រឹងការគ្រប់គ្រង និងថែរក្សាសត្វព្រៃ
- ការជួសជុល និងការថែទាំប្រព័ន្ធធារាសាស្ត្រ ការសម្របសម្រួល ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ទន្លេសាប ការជួសជុល និងការថែទាំស្ថានីយឧតុនិយមស្វ័យប្រវត្តិ និងមិនស្វ័យប្រវត្តិ ការជួសជុល និងការថែទាំម៉ាស៊ីនបូមទឹកចល័ត និងស្ថានីយបូមទឹក ព្រមទាំងការត្រៀមលក្ខណៈឱ្យបានល្អសម្រាប់កិច្ចអន្តរាគមន៍ជួយប្រជាពលរដ្ឋ ពេលមានគ្រោះរាំងស្ងួត និងទឹកជំនន់ជាយថាហេតុ
- ការជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ និងការជីកស្រះ និងអណ្តូងទឹក
- ការលើកកម្ពស់អនាម័យតាមសហគមន៍ជនបទ
- ការគាំទ្រដំណើរការរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍ-សេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ការគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ការលើកម្ពស់គុណភាពស្តង់ដា និងការអភិវឌ្ឍវិស័យមាត្រាសាស្ត្រ រួមទាំងការគ្រប់គ្រងទិន្នន័យទីតាំងភូមិសាស្ត្ររោងចក្រ
- ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ និងការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងអាជ្ញាប័ណ្ណអាជីវកម្មរ៉ែសំណង់
- ការគ្រប់គ្រងនិងអភិវឌ្ឍវិស័យថាមពល
- ការអភិវឌ្ឍធនធាន និងគោលដៅទាក់ទាញទេសចរណ៍ ព្រមទាំងការគ្រប់គ្រង និងការលើកកម្ពស់កិត្តិនាមទេសចរណ៍ និងការអភិវឌ្ឍទេសចរណ៍ ដោយផ្តោតលើការជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍ ព្រមទាំងការឃោសនាផ្សព្វផ្សាយ ដើម្បីទាក់ទាញផង និងជួយបង្កើនតម្លៃបន្ថែមរបស់វិស័យនេះផង
- ការរៀបចំគោលនយោបាយអភិវឌ្ឍវិស័យអាកាសចរណ៍ស៊ីវិល ការគ្រប់គ្រងប្រតិបត្តិការនិងសេវាកម្មអាកាសចរណ៍ស៊ីវិល និងការកែលម្អសុវត្ថិភាព និងសន្តិសុខអាកាសចរណ៍ស៊ីវិល
- ការបន្តពង្រឹងការផ្តល់សេវាសាធារណៈផ្នែកពាណិជ្ជកម្ម ដូចជា ការថែទាំប្រព័ន្ធស្វ័យប្រវត្តិកម្មបញ្ជាក់ប្រភពដើមទំនិញ ការគ្រប់គ្រងថែទុករក្សាទិន្នន័យក្រុមហ៊ុន-សហគ្រាស និងការស្វែងរកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា ជាដើម

- ការត្រួតពិនិត្យទំនិញ ការផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់ និងការត្រួតពិនិត្យបញ្ជាក់ទៅលើវិធានបទប្បញ្ញត្តិពាក់ព័ន្ធអនុវត្តច្បាប់កិច្ចការពារអ្នកប្រើប្រាស់
- ការបន្តពង្រឹងការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ពិសេសការលើកកម្ពស់គុណភាព ប្រសិទ្ធភាព សុវត្ថិភាព និងសន្តិសុខសាយប័រ ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ឈានទៅអនុវត្តសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។

ទន្ទឹមនេះ ក្រៅពីថវិកាចំណាយចរន្តដែលត្រូវបានវិភាជជូនក្រសួង-ស្ថាប័ន សម្រាប់អនុវត្តកម្មវិធី និងសកម្មភាពការងារអាទិភាពដូចបានជម្រាបជូនខាងលើ ក្រសួង ស្ថាប័នមួយចំនួនក្នុងវិស័យសេដ្ឋកិច្ចក៏ទទួលបានផងដែរនូវថវិកាគម្រោងវិនិយោគផ្ទាល់ ដូចមានឆ្លុះបញ្ចាំងក្នុង **ឧបសម្ព័ន្ធទី២**។

**៥-ចំណាយមិនទាន់បែងចែកមានមុខសញ្ញានៃចំណាយចរន្ត** ត្រូវបានគ្រោងចំនួន៣ **៧៦៧ប៊ីលានរៀល** មានសមាមាត្រស្មើនឹង១៥,៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ និងត្រូវជា១,៨០% នៃ ផ.ស.ស.។ ចំណាយនេះ មួយផ្នែក គឺមានមុខសញ្ញាចំណាយច្បាស់លាស់រួចហើយ តែតម្រូវឱ្យកត់ត្រាក្នុងខ្ទង់ចំណាយមិនទាន់បែងចែកនេះសិន ដោយសារការតម្រូវខាងទិដ្ឋភាពបច្ចេកទេសដែលកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន និងមួយផ្នែកទៀតគឺចំណាយត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងចំណាយលើមុខសញ្ញាមិនបានគ្រោងទុក។ ចំណាយមានមុខសញ្ញាទាំងនេះ រួមមានដូចខាងក្រោម៖

**៥.១-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា**

- ចំណាយចរន្តក្នុងការអនុវត្តគម្រោង (បដិភាគចំណាយចរន្ត) ត្រូវបានត្រៀមថវិកាចំនួន ២២៥ប៊ីលានរៀល សមមូលនឹងប្រមាណ៥៥លានដុល្លារអាមេរិក ស្មើនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលចំណាយនេះ ត្រូវបានបើកផ្តល់ជូនក្រសួង ស្ថាប័នស្របតាមតម្រូវការជាក់ស្តែង ដើម្បីជាបដិភាគជាមួយគម្រោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេស។

- ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រោងថវិកាចំនួន១ ៨៦៩ប៊ីលានរៀល សមមូលនឹងប្រមាណ៤៥៩លានដុល្លារអាមេរិក កើនចំនួន១៥០ប៊ីលានរៀល ត្រូវជា៨,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលចំណាយនេះ នឹងត្រូវធ្វើការផ្ទេរភ្លាមដើម្បីបំពេញគុណភាពថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមគោលដៅដែលបានគ្រោងទុក តាមនីតិវិធីហិរញ្ញវត្ថុ ក្រោយពេលដែលច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំចូលជាធរមាន។

**៥.២-ចំណាយត្រៀមបម្រុង និងមិនបានគ្រោងទុកតាមមុខសញ្ញា**

- ថវិកាត្រៀមបម្រុងសម្រាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល រួមទាំង កិច្ចការអធិបតេយ្យ ត្រូវបានត្រៀមថវិកាចំនួន៣៥០ប៊ីលានរៀល។

- ថវិកាត្រៀមបម្រុងផ្សេងៗ សម្រាប់ដោះស្រាយតម្រូវការចាំបាច់ជាយថាហេតុ របស់រាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័ន ត្រូវបានគ្រោងចំនួន២៧១,៦ប៊ីលានរៀល។

- ថវិកាត្រៀមបម្រុងសម្រាប់គ្រោះធម្មជាតិ ត្រូវបានគ្រោងចំនួន២០០ប៊ីលានរៀល។

- ថវិកាត្រៀមបម្រុងមានមុខសញ្ញា ដែលជាកម្មវត្ថុនៃការផ្ទេរទៅតាមក្រសួង-ស្ថាប័ន ក្នុងអំឡុងពេលអនុវត្តត្រូវបានគ្រោង៤២១ប៊ីលានរៀល, ក្នុងនោះ ថវិកាត្រៀមបម្រុងដែលនឹងត្រូវផ្ទេរទៅតាមក្រសួង-ស្ថាប័ន សម្រាប់អនុវត្តការងារអាទិភាពដែលក្រសួង ស្ថាប័នបានស្នើឡើង តែមិនទាន់មានគម្រោង និងផែនការអនុវត្តច្បាស់លាស់ មានទំហំសរុបចំនួន១១៨ប៊ីលានរៀល។

៥.៣-ចំណាយត្រៀមបម្រុងសម្រាប់វិធានការគន្លឹះ និងការជំរុញកំណើន ត្រូវបានត្រៀមថវិកាចំនួន៤៣០ប៊ីលានរៀល រួមមាន៖

- វិធានការគន្លឹះផ្សេងៗ ចំនួន២០៥ប៊ីលានរៀល ក្នុងនោះ ថវិកាសម្រាប់ការបន្តការកែទម្រង់រដ្ឋបាលសាធារណៈ ចំនួន១២០ប៊ីលានរៀល
- កម្មវិធីជំរុញការប្រើប្រាស់ និងលើកកម្ពស់សកម្មភាពទេសចរណ៍ ចំនួន៦១ប៊ីលានរៀល
- គម្រោងសាច់ប្រាក់ពលកម្មសម្រាប់គាំទ្រគោលដៅសង្គមច្បាស់លាស់ ចំនួន៤២ប៊ីលានរៀល
- កម្មវិធីគាំពារសង្គមដើម្បីចាកចេញពីភាពក្រីក្រ ចំនួន១២ប៊ីលានរៀល
- កញ្ចប់អន្តរាគមន៍ជំរុញកំណើនផ្សេងៗ ចំនួន១១០ប៊ីលានរៀល។

**១៦**- ចំណាយមូលធនថ្នាក់ជាតិ ឆ្នាំ២០២៥ ត្រូវបានគ្រោងចំនួន១១ ៤៩៦ប៊ីលានរៀល មានសមាមាត្រស្មើនឹង៣២,៥%នៃចំណាយសរុបថវិកាថ្នាក់ជាតិ ត្រូវជា៥,៥% នៃផ.ស.ស. ឬកើនចំនួន៧,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ គម្រោងចំណាយមូលធននេះ ត្រូវបានបែងចែកដូចខាងក្រោម៖

១-គម្រោងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន៤ ៦២៥ប៊ីលានរៀល ត្រូវជា២,២១% នៃផ.ស.ស. ឬកើនចំនួន៣,២%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្នុងនោះ គម្រោងចំណាយវិនិយោគផ្ទាល់ចំនួន១ ៨៥៣ប៊ីលានរៀល ត្រូវបានបែងចែក ដូចខាងក្រោម៖

១.១-ចំណាយវិនិយោគផ្ទាល់ចំនួន៧១៩ ១០០លានរៀល ត្រូវបានបែងចែកតាមក្រសួងអាទិភាពចំនួន ១១ (ថយ១០ ២២០លានរៀល ធៀបនឹងឆ្នាំ២០២៤) ដោយផ្តោតអាទិភាពទៅលើ៖

- ការបន្តជួសជុល ស្តារ កែលម្អ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន លូ ព្រមទាំងការជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកកខ្វក់
- ការបន្តជួសជុលស្តារ កែលម្អ និងកសាងប្រព័ន្ធធារាសាស្ត្រ
- ការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មគ្រាប់ពូជស្រូវ និងការសាងសង់ស្ថានីយស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទំនើបបឹងទន្លេសាប នៅខេត្តកំពង់ឆ្នាំង
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ព្រមទាំងការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាល និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

សូមជូនឧបសម្ព័ន្ធទី២ : គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ ដែលជាឯកសារព័ត៌មានបន្ថែម ស្តីពីបញ្ជីគម្រោងវិនិយោគផ្ទាល់តាមក្រសួង ស្ថាប័ន ដោយអនុលោមតាមមាត្រា៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**១.២-ចំណាយត្រៀមបម្រុងផ្សេងៗ និងមិនបានគ្រោងទុកសរុបចំនួន៥៦៨ ៣៩៩លានរៀល** (ថយចំនួន៩១ ៦០១លានរៀល ធៀបនឹងឆ្នាំ២០២៤) សម្រាប់អនុវត្តចំណាយក្រោមការសម្រេចផ្ទាល់ដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ក្នុងនោះមានជាអាទិ៍៖

- សម្រាប់ក្រសួង ស្ថាប័នផ្សេងៗ ក្រៅពីក្រសួងអាទិភាពទាំង ១១ ត្រូវបានគ្រោងចំនួន ១០៨ ៣៩៩លានរៀល សម្រាប់អនុវត្តបន្តគម្រោងមួយចំនួនមានលក្ខណៈជាការអនុវត្តពហុឆ្នាំ និងគម្រោង អាទិភាពថ្មីៗមួយចំនួនទៀត។
- សម្រាប់ទូទាត់គម្រោងដែលបានជានាចំណាយពីឆ្នាំមុនៗ ត្រូវបានគ្រោងចំនួន២០០ ០០០លានរៀល (ថយចុះចំនួន១០០ ០០០លានរៀល ធៀបនឹងឆ្នាំ២០២៤)។
- សម្រាប់ជួសជុលស្តារហេដ្ឋារចនាសម្ព័ន្ធដែលរងការខូចខាតដោយគ្រោះធម្មជាតិ ត្រូវបានគ្រោងចំនួន១២០ ០០០លានរៀល (រក្សាស្មើនឹងឥណទានថវិកាឆ្នាំ២០២៤)។
- សម្រាប់ចំណាយគម្រោងការពារបាក់ច្រាំងទន្លេតាមបណ្តោយទន្លេមេគង្គ ត្រូវបានគ្រោងចំនួន៦០ ០០០លានរៀល (រក្សាស្មើនឹងឥណទានថវិកាឆ្នាំ២០២៤) ។
- ចំណាយត្រៀមបម្រុងសម្រាប់អន្តរាគមន៍ចាំបាច់ផ្សេងៗ ដូចជាគ្រោះធម្មជាតិ ជាដើម។

**១.៣-ចំណាយត្រៀមបម្រុងអន្តរាគមន៍សង្គម សេដ្ឋកិច្ច ត្រូវបានគ្រោងសរុបចំនួន៣១១ ៣២៣លានរៀល** (ថយចំនួន១ ០៣៣ ៤៧៧លានរៀល ធៀបនឹងឆ្នាំ២០២៤) សម្រាប់បញ្ចប់ការងាររូបវន្តនៃគម្រោងតំបន់អភិវឌ្ឍន៍រុនតាឯក និងការថែទាំហេដ្ឋារចនាសម្ព័ន្ធនៃគម្រោងតំបន់អភិវឌ្ឍន៍ពាក់ស្នែង ក្នុងខេត្តសៀមរាប។

**១.៤-ការវិនិយោគទុនរួមគ្នា ត្រូវបានគ្រោងចំនួន១៣១ ២៩២លានរៀល** (ថយចំនួន៨៧ ៨៩៩លានរៀល ធៀបនឹងឆ្នាំ២០២៤)៖ សម្រាប់ចូលរួមវិភាគទានជាកាតព្វកិច្ចស្របតាមកិច្ចព្រមព្រៀងជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអភិវឌ្ឍន៍អេកម៉ិ និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្មចំនួន១១ ៨៧០លានរៀល។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលគ្រោងថវិកាដែលបានមកពីការបោះផ្សាយមូលបត្រ ក្នុងទំហំ១១៩ ៤២២លានរៀល សមមូលនឹងប្រមាណ២៩លានដុល្លារអាម៉េរិក សម្រាប់ការអនុវត្តគម្រោងវិនិយោគសាធារណៈដែលហុចផលឆាប់រហ័ស។

**១.៥-ចំពោះថវិកាដែលបានពី*ការបោះផ្សាយមូលបត្ររដ្ឋ*** ចំនួន១២២ ០៧០លានរៀលផ្សេងទៀត ត្រូវបានគ្រោងសម្រាប់ឱ្យធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារសហគ្រាសធុនតូច និងមធ្យម ខ្ចីបន្ត ដើម្បីផ្តល់ឥណទានដល់វិស័យឯកជនសម្រាប់ការវិនិយោគលើវិស័យអាទិភាពក្នុងបណ្តាខេត្តទិសពៀសាន។

**២-គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងចំនួន៦ ៨៧១ប៊ីលានរៀល** ត្រូវជា៣,២៩% នៃផ.ស.ស. ឬកើនចំនួន១០,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ស្មើនឹងប្រមាណ១៨,១%នៃចំណាយថវិកាជាតិសរុបឆ្នាំ២០២៥។ គម្រោងចំណាយនេះ គឺជាតួលេខ

ប៉ាន់ស្មាននៃការបើកផ្តល់សាច់ប្រាក់ ទាំងឥណទានសម្បទាន និងទាំងហិរញ្ញប្បទានឥតសំណង ពីដៃគូអភិវឌ្ឍន៍សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈកំពុងដំណើរការ ដែលបាន ចុះហត្ថលេខា មុននិងក្នុងឆ្នាំ២០២៥។

សូមជូន**ឧបសម្ព័ន្ធទី៣** : គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ដែលជាឯកសារព័ត៌មានបន្ថែម ស្តីពីបញ្ជីគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសតាមក្រសួង ស្ថាប័ន ដោយអនុលោមតាមមាត្រា៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**១៧**- ការកំណត់ពិតាននៃការខ្ចី : រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីប្រាក់ពីក្នុងប្រទេស និងពីដៃគូអភិវឌ្ឍន៍ ដូចខាងក្រោម៖

*(១)-គ្រោងធ្វើការបោះផ្សាយមូលបត្ររដ្ឋចំនួន៥០០ប៊ីលានរៀល សមមូលនឹងប្រមាណ ១២៣លានដុល្លារអាមេរិក* សម្រាប់ហិរញ្ញប្បទានលើចំណាយវិនិយោគ និងរក្សាគុល្យភាពថវិកាជាតិ។

*(២)-កំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍ចំនួន២ ០០០លានអេសដេអ៊ែ សមមូលនឹងប្រមាណ២,៧ប៊ីលានដុល្លារអាមេរិក* កើនចំនួន៣០០លានអេសដេអ៊ែ ពីឆ្នាំ២០២៤ ដោយផ្អែកលើទិដ្ឋភាព៖ (១)-ទំហំនៃតម្រូវការវិនិយោគសាធារណៈដែលកម្ពុជាមានភាពចាំបាច់ក្នុងការកៀរគរធនធានបន្ថែមឱ្យបានច្រើន ដើម្បីបំពេញតម្រូវការសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ជាពិសេសដើម្បីជំនួសថវិកាគម្រោងវិនិយោគសាធារណៈដោយប្រភពចំណូលក្នុងប្រទេស ដែលត្រូវធ្វើវិចារណកម្ម ដើម្បីបំពេញតម្រូវការចំណាយចរន្ត ក្នុងបរិការណ៍ដែលប្រភពចំណូលក្នុងប្រទេស ជាពិសេសចំណូលសារពើពន្ធមាននិន្នាការថមថយ, (២)-កម្មវិធី/គម្រោងអភិវឌ្ឍន៍ដែលនឹងចុះកិច្ចព្រមព្រៀងឥណទានសម្បទានក្នុងឆ្នាំ២០២៥ ជាកម្មវិធី/គម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបង្កើនផលិតភាពសេដ្ឋកិច្ច និងផលិតភាពផលិតកម្ម) ដែលមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងវែង, (៣)-ឥណទានមានកម្រិតសម្បទានខ្ពស់ (៤)-ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមនៅ តែមាន "**ចីរភាព**" និង "**ហានិភ័យកម្រិតទាប**" និង (៥)-ការបន្តបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង។ ដូចបានបង្ហាញជូនជាព័ត៌មានបន្ថែមក្នុង**ឧបសម្ព័ន្ធទី៣** កម្មវិធី/គម្រោងអភិវឌ្ឍន៍សំខាន់ៗ ត្រូវបានបែងចែកតាមវិស័យដូចខាងក្រោម៖

- **វិស័យថាមពលចំនួន៦កម្មវិធី/គម្រោង** គឺគម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ដំហានទី២ គម្រោងអភិវឌ្ឍន៍បណ្តាញអគ្គិសនីប្រកបដោយចីរភាព គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទដំហានទី២ កម្មវិធីអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីអន្តរកាល-អនុកម្មវិធីទី២ គម្រោងពង្រីកសមត្ថភាពប្រព័ន្ធបណ្តាញ បញ្ជូនថាមពលអគ្គិសនីអន្តរកាល និងគម្រោងពង្រីកប្រព័ន្ធបញ្ជូននិងចែកចាយអគ្គិសនី ដំហានទី៣។
- **វិស័យទឹកស្អាតចំនួន៥គម្រោង** គឺគម្រោងពង្រីកការផ្គត់ផ្គង់ទឹកស្អាតនិរោធ គម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវការផ្គត់ផ្គង់ទឹកស្អាតនៅភាគខាងត្បូងរាជធានីភ្នំពេញ គម្រោងប្រព័ន្ធគ្រប់គ្រងទឹកឆ្លាតវៃ គម្រោងពង្រីកបណ្តាញចែកចាយទឹកស្អាត និងសេវាទឹកស្អាត និងគម្រោងអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងប្រកបដោយចីរភាព។

- **វិស័យធារាសាស្ត្រចំនួន៤កម្មវិធី/គម្រោង** គឺគម្រោងអភិវឌ្ឍន៍ធនធានទឹកជុំគិរី ខេត្តកំពត កម្មវិធីគ្រប់គ្រងធនធានទឹកនិងការផ្លាស់ប្តូរវិស័យកសិកម្មសម្រាប់ប្រទេសកម្ពុជា ជំហានទី២ គម្រោងពង្រឹងសមត្ថភាពធន់ទ្រាំនៃជនបទ គម្រោងគ្រប់គ្រងទឹក ការស្រោចស្រព បង្ការទឹកជំនន់ និងការរាំងស្ងួត ប្រកបដោយចីរភាពជំហានទី១។
- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តចំនួន៩កម្មវិធី/គម្រោង** គឺកម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់ប្រទេសកម្ពុជាជំហានទី២ គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ (ហិរញ្ញប្បទានបន្ថែម) គម្រោងសាងសង់ផ្លូវជាតិលេខ ៥០C ពីខេត្តកំពង់ឆ្នាំងទៅខេត្តកំពង់ធំ និងស្ពានឆ្លងទន្លេសាប គម្រោងធ្វើឱ្យប្រសើរឡើងសេវាទីក្រុងដែលធន់នឹងការប្រែប្រួលអាកាសធាតុជំហានទី១ គម្រោងធ្វើឱ្យប្រសើរឡើងកំណាត់ផ្លូវក្នុងតំបន់ គម្រោងលើកកម្រិត និងពង្រីកផ្លូវប្រាសាទ គម្រោងធ្វើឱ្យប្រសើរឡើងវិញកំណាត់ផ្លូវជាតិលេខ៦៨ (ក្រឡាញ់-សំរោង-អូរស្មាច់) គម្រោងច្រកទ្វារអន្តរជាតិស្ទឹងបត់និងផ្លូវតភ្ជាប់ផ្លូវជាតិលេខ៥ ជំហានទី២ គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី (ឥណទានបន្ថែម)។
- **វិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន១គម្រោង** គឺគម្រោងអភិវឌ្ឍន៍វិស័យអប់រំកម្រិតមូលដ្ឋាន។
- **វិស័យសុខាភិបាលចំនួន២គម្រោង** គឺគម្រោងគាំទ្របន្ទាន់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងគម្រោងទប់ស្កាត់និងបង្ការជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គជំហានទី២។
- **វិស័យកសិកម្មចំនួន២គម្រោង** គឺគម្រោងពិពិធកម្មទីផ្សារនិងពាណិជកម្មកសិកម្ម ដែលធន់នឹងការប្រែប្រួលអាកាសធាតុ និង គម្រោងជំរុញបរិវត្តកម្មវិស័យកសិកម្ម។
- **វិស័យអាទិភាពផ្សេងទៀតចំនួន៥កម្មវិធី/គម្រោង** គឺកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ប្រកបដោយបរិយាបន្ន អនុកម្មវិធីទី១ កម្មវិធីពង្រឹងអភិបាលកិច្ចការផ្តល់សេវា អនុកម្មវិធីទី១ គម្រោងរៀបចំបង្កើតមូលនិធិហិរញ្ញប្បទានអាកាសធាតុកម្ពុជា កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងការប្រកួតប្រជែង អនុកម្មវិធីទី៣ និងកម្មវិធីការផ្តល់ហិរញ្ញប្បទានដើម្បីអភិវឌ្ឍន៍គោលនយោបាយ និងភាពធន់របស់កម្ពុជា ជំហានទី៣។

គួរគូសបញ្ជាក់ថា ការបោះផ្សាយលក់មូលបត្ររដ្ឋ និងការខ្ចីពីក្រៅប្រទេសក្នុងទំហំខាងលើនេះនឹងមិនបង្កើតជាបន្ទុកបំណុលល្អែកដល់កម្ពុជាទេ ពោលគឺជាទិដ្ឋភាពបច្ចេកទេស ស្ថានភាពបំណុលសាធារណៈកម្ពុជានៅតែត្រូវបានវាយតម្លៃថា មានចីរភាពនិងហានិភ័យកម្រិតទាប ដដែល ដោយរាល់សូចនាករបំណុលគន្លឹះៗរបស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

**១៨**- គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់) ត្រូវបានរៀបចំឡើងដោយឈរលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងរាល់ក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធមានជាធរមាន។ ចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់) ឆ្នាំ២០២៥ ត្រូវបានគ្រោងដូចខាងក្រោម៖

| សូចនាករថវិកាថ្នាក់ក្រោមជាតិ | ២០២៣ | | ២០២៤ | ២០២៥ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណូលសរុបថវិកា(%ផ.ស.ស.) | ១,៤៧ | ១,៤៣ | ១,៣៦ | ១,២២ |
| ចំណូលចរន្ត (%ផ.ស.ស.) | ១,៤៧ | ១,៣៥ | ១,២៩ | ១,២០ |
| ចំណាយផ្សេងៗ (%ផ.ស.ស.) | ០,០ | ០,០៨ | ០,០៨ | ០,០២ |
| ចំណាយសរុបថវិកា (%ផ.ស.ស.) | ២,២៩ | ២,៨១ | ២,២៦ | ២,១១ |
| ចំណាយចរន្ត (%ផ.ស.ស.) | ២,០ | ២,៣៤ | ១,៩៨ | ១,៩២ |
| ចំណាយមូលធន(%ផ.ស.ស.) | ០,២៩ | ០,៤៨ | ០,២៨ | ០,១៩ |

• ចំណូលសរុបថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបានគ្រោងចំនួន២ ៥៥២ប៊ីលានរៀល មានសមាមាត្រស្មើនឹង៨,១% នៃចំណូលសរុបថវិការដ្ឋ ត្រូវជា១,២២% នៃផ.ស.ស. ឬថយចំនួន២,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្នុងនោះរួមមាន៖

- ចំណូលសារពើពន្ធ ត្រូវបានគ្រោងចំនួន២ ២១៩ប៊ីលានរៀល ត្រូវជា១,០៦% នៃផ.ស.ស. ឬកើនចំនួន០,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤
- ចំណូលមិនមែនសារពើពន្ធ ត្រូវបានគ្រោងចំនួន៣០១ប៊ីលានរៀល ត្រូវជា០,១៤% នៃផ.ស.ស. ឬកើនចំនួន១៨,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤
- ចំណូលផ្សេងៗ ត្រូវបានគ្រោងចំនួន៣៣ប៊ីលានរៀល ត្រូវជា០,០២% នៃផ.ស.ស.។

• ចំណាយសរុបថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រោងចំនួន៤ ៤២១ប៊ីលានរៀល មានសមាមាត្រស្មើនឹង១១,៧% នៃចំណាយសរុបថវិការដ្ឋ ត្រូវជា២,១១% នៃផ.ស.ស. ឬកើនចំនួន២,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្នុងនោះ៖

ក. ចំណាយចរន្ត ត្រូវបានគ្រោងចំនួន៤ ០២២ប៊ីលានរៀល មានសមាមាត្រស្មើនឹង១៥,៤% នៃចំណាយចរន្តសរុបថវិការដ្ឋ ត្រូវជា១,៩២% នៃផ.ស.ស. ឬកើនចំនួន៥,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។ ក្នុងទំហំចំណាយចរន្តនេះ ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ នឹងត្រូវដំឡើងជូន ដោយគិតអនុវត្តសម្រាប់រយៈពេល ១២ខែ គឺពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥ ដូចខាងក្រោម៖

ក.១ ក្រុមប្រឹក្សារាជធានី ខេត្ត

- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវបានដំឡើងពី១ ៦៥០ ០០០រៀល នៅឆ្នាំ២០២៤ ទៅដល់១ ៦៨៥ ០០០រៀល នៅឆ្នាំ២០២៥
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវបានដំឡើងពី១ ២៤៥ ០០០រៀល នៅឆ្នាំ២០២៤ ទៅដល់១ ២៨០ ០០០រៀល នៅឆ្នាំ២០២៥

ក.២ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងត្រូវបានដំឡើងពី១ ៣៦៥ ០០០ រៀល នៅឆ្នាំ២០២៤ ទៅដល់១ ៣៩៥ ០០០រៀល នៅឆ្នាំ២០២៥

- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងត្រូវបានដំឡើងពី១ ០២០ ០០០ រៀល នៅឆ្នាំ២០២៤ ទៅដល់១ ០៥០ ០០០រៀល នៅឆ្នាំ២០២៥

ក.៣ ក្រុមប្រឹក្សាឃុំ សង្កាត់

- ប្រាក់បំណាច់មេឃុំ ចៅសង្កាត់ នឹងត្រូវបានដំឡើងពី១ ៣២០ ០០០រៀល នៅឆ្នាំ២០២៤ ទៅដល់១ ៣៤៥ ០០០រៀល នៅឆ្នាំ២០២៥
- ប្រាក់បំណាច់ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ នឹងត្រូវបានដំឡើងពី៩៨០ ០០០ រៀល នៅឆ្នាំ២០២៤ ទៅដល់១ ០០៥ ០០០រៀល នៅឆ្នាំ២០២៥
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវបានដំឡើងពី៨៧០ ០០០រៀល នៅឆ្នាំ២០២៤ ទៅដល់៨៩៥ ០០០រៀល នៅឆ្នាំ២០២៥
- ប្រាក់បំណាច់មេភូមិ នឹងត្រូវបានដំឡើងពី៥៥០ ០០០រៀល នៅឆ្នាំ២០២៤ ទៅដល់ ៥៧០ ០០០រៀល នៅឆ្នាំ២០២៥
- ប្រាក់បំណាច់អនុប្រធានភូមិ នឹងត្រូវបានដំឡើងពី៤៣០ ០០០រៀល នៅឆ្នាំ២០២៤ ទៅដល់៤៤៥ ០០០រៀល នៅឆ្នាំ២០២៥
- ប្រាក់បំណាច់សមាជិកភូមិ នឹងត្រូវបានដំឡើងពី៤០០ ០០០រៀល នៅឆ្នាំ២០២៤ ទៅដល់៤១៥ ០០០រៀល នៅឆ្នាំ២០២៥។

លើសពីនេះទៀត គួរកត់សម្គាល់ថា ទំហំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជម្រាបជូនខាងលើ នៅមិនទាន់គិតបញ្ចូលនូវកញ្ចប់ថវិការបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងកញ្ចប់ថវិកានៃការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ រួមមានការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ និងមុខងារចំនួន៣ផ្សេងទៀត ដែលរួមមាន : មុខងារគ្រប់គ្រងការអប់រំកុមារតូច មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និងមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ទៅឱ្យគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ទូទាំងប្រទេស។ ដូចនេះ បើគិតបញ្ចូលទាំងកញ្ចប់ថវិកានៃការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌនេះ ដែលត្រូវផ្ទេរជូនភ្លាម បន្ទាប់ពីច្បាប់ហិរញ្ញវត្ថុត្រូវបានអនុម័ត ក្នុងក្របខ័ណ្ឌនៃការអនុវត្តថវិកា កញ្ចប់ថវិកាចំណាយចរន្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានទំហំសរុបស្មើនឹង៦ **៧៩៤ប៊ីលានរៀល** មានសមាមាត្រស្មើនឹង២៦,១%នៃចំណាយចរន្តសរុបថវិការដ្ឋត្រូវជា៣,២៥% នៃផ.ស.ស. ឬកើនចំនួន ៥,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

**ខ. ចំណាយមូលធន** ត្រូវបានគ្រោងចំនួន៤០០ប៊ីលានរៀល មានសមាមាត្រ៨,០%នៃចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវជា០,១៩% នៃផ.ស.ស. ឬថយចំនួន២៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

គម្រោងចំណូល ចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ខាងលើ បានធ្វើឱ្យមានឱនភាពថវិកាចំនួន១ ៨៦៩ប៊ីលានរៀល ត្រូវជា០,៨៩% នៃផ.ស.ស. ហើយត្រូវបានគ្រោងឧបត្ថម្ភធនបំពេញតុល្យភាពដោយថវិកាថ្នាក់ជាតិ ដូចតទៅ : (១)-ឧបត្ថម្ភរាជធានី ខេត្ត (សម្រាប់រដ្ឋបាលខណ្ឌ) ចំនួន១៣ប៊ីលានរៀល ថយចំនួន១៤,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ (២)-ឧបត្ថម្ភមូលនិធិក្រុង ស្រុក ចំនួន៥៥៩ប៊ីលានរៀល កើនចំនួន១,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤

(៣)-ឧបត្ថម្ភមូលនិធិឃុំ សង្កាត់ចំនួន១ ០០៩ប៊ីលានរៀល កើនចំនួន១២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ និង (៤)-មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ចំនួន២៨៨ប៊ីលានរៀល កើនចំនួន១២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលជាការផ្ទេរធនធានបន្ថែមពីលើមូលនិធិឃុំ សង្កាត់ ជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។ ការឧបត្ថម្ភធនបន្ថែម នេះនឹងធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗទទួលបានថវិកាសរុបជាមធ្យមប្រមាណ៧៨៥លានរៀល សមមូលនឹង១៩៣ ០០០ដុល្លារអាម៉េរិក ក្នុងនោះ ថវិកាសម្រាប់ផ្នែកអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់នីមួយៗ ទទួលបានជាមធ្យមប្រមាណ៤៥៧លានរៀល ឬសមមូលនឹង១១២ ០០០ដុល្លារអាម៉េរិក ក្នុង១ឆ្នាំ កើនឡើង១០,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

**១៩**- នៅក្នុងក្របខ័ណ្ឌថវិកាខាងលើ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តបានក្នុងកម្រិតប្រមាណ២,០៧% នៃផ.ស.ស. នៅឆ្នាំ២០២៥ ដែលជាលទ្ធផល ឱនភាពសរុបថវិកាជាតិនឹងមានទំហំស្មើនឹង-៣,០៤% នៃផ.ស.ស.។ ដូចនេះ រាជរដ្ឋាភិបាលមានតម្រូវការហិរញ្ញប្បទានទំហំ៣,០៤% នៃផ.ស.ស. ដើម្បីបំពេញឱនភាពថវិកាជាតិ ព្រមទាំងមានតម្រូវការហិរញ្ញប្បទានទំហំ១,១៦% នៃផ.ស.ស. ស្មើនឹង២ ៤២៨ប៊ីលានរៀល សម្រាប់ការទូទាត់ប្រាក់ខ្ចី ដើម្បីរំលស់បំណុលសាធារណៈក្នុងប្រទេស និងក្រៅប្រទេស ស្របតាមវិធាននិងនីតិវិធីថ្មីនៃការទូទាត់ប្រាក់ខ្ចីដែលបានកំណត់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣។ ជាសរុប សម្រាប់ថវិកាឆ្នាំ២០២៥ រាជរដ្ឋាភិបាលមានតម្រូវការហិរញ្ញប្បទានក្នុងទំហំ៤,២០% នៃផ.ស.ស. ដែលនឹងត្រូវបានគាំទ្រដោយហិរញ្ញប្បទានក្នុងប្រទេស តាមរយៈការបោះផ្សាយមូលបត្ររដ្ឋក្នុងទំហំ៥០០ប៊ីលានរៀល សមមូលនឹងប្រមាណ១២៣លានដុល្លារអាម៉េរិក និងហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ៣,៩៦% នៃផ.ស.ស. ក្នុងនោះមានមូលនិធិទ្រទ្រង់ថវិកាទំហំ០,៩៤% នៃផ.ស.ស. និងថវិកាវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសទំហំ៣,០១% នៃផ.ស.ស.។

## III-បញ្ហាប្រឈមនិងវិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥

**២០**- ការអនុវត្តក្របខ័ណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំជម្នះនូវការលំបាក និងបញ្ហាប្រឈមមួយចំនួន ទាំងផ្នែកចំណូល ទាំងផ្នែកចំណាយ ដូចខាងក្រោម៖

ក-ផ្នែកចំណូល

**ទី១**- សម្ទុះកំណើនចំណូលនៅមានសភាពយឺតនៅឡើយ ដោយសារម្យ៉ាង កំណើនក្នុងវិស័យដែលជាប្រភពចំណូលថវិកាជាតិមានការងើបឡើងវិញយឺតៗ និងម្យ៉ាងទៀត ដោយសាររាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយលើកទឹកចិត្តផ្នែកសារពើពន្ធលើវិស័យអាទិភាពមួយចំនួនដើម្បីជំរុញផលិតកម្មក្នុងស្រុក និងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ក៏ដូចជាដើម្បីគាំទ្រការអភិវឌ្ឍវិស័យអាទិភាពផ្សេងៗ និងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសដៃគូព្រមជាមួយការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាដើម។

**ទី២**- ការគ្រប់គ្រង និងការប្រមូលចំណូលពន្ធដារ អាចជួបប្រឈមនឹងបញ្ហាមួយចំនួនចំពោះមុខដូចជា : (១)- ការផលិត និងការចែកចាយផលិតផលសុរា និងថ្នាំជក់ក្លែងក្លាយ និងការគេចពន្ធនានា

(២)-ការកែសម្រួលការអនុវត្តវិធានការពន្ធដារចាំបាច់នានា ជាពិសេសយន្តការសវនកម្ម (៣)-ការផ្តល់ការលើកទឹកចិត្តលើកលែងពន្ធក្នុងវិស័យមួយចំនួនបន្ថែមទៀត (៤)-ការរារែកក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធមួយចំនួន និង (៥)-ការបន្តបំផ្លើស បំភ្លៃ និងបំភាន់មតិសាធារណៈឱ្យមានការយល់ខុស និងមានទស្សនអវិជ្ជមាន ដោយជនឆ្លៀតឱកាសមួយចំនួនក្នុងគោលដៅវាយប្រហារស្ថាប័នប្រមូលចំណូល ។

ទី៣- ការគ្រប់គ្រង និងការប្រមូលចំណូលពន្ធគយ អាចជួបប្រឈមនឹងបញ្ហាមួយចំនួនចំពោះមុខ ដូចជា : (១)-ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី មានទំហំកាន់តែកើនឡើង និងកាន់តែស៊ីជម្រៅ (២)-ការអនុគ្រោះពន្ធនិងអាករលើយន្តការលើកទឹកចិត្តលើការវិនិយោគដោយដាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ និងការលើកទឹកចិត្តលើវិស័យអាទិភាពនានា ដូចជា ឧស្សាហកម្មផ្គុំដំឡើងយានយន្តក្នុងប្រទេស (៣)-និន្នាការកើនឡើងនូវការប្រើប្រាស់រថយន្តមានទំហំស៊ីឡាំងតូចនិងរថយន្តប្រើប្រាស់ថាមពលអគ្គិសនីដែលមានអត្រាពន្ធទាប (៤)-កំណើនផលិតកម្មក្នុងស្រុក មួយចំនួនជំនួសការនាំចូល (៥)-អនុលោមភាពដោយស្ម័គ្រចិត្តរបស់ធុរជននៅមានកម្រិតនិងការប្រើប្រាស់វិធីសាស្ត្រថ្មីៗក្នុងការបន្លំពន្ធ (៦)-ភាពចាំបាច់នៃការបន្តបញ្ចុះអត្រាពន្ធអាករ ដើម្បីជួយគាំទ្រវិស័យអាទិភាពនានា ជាពិសេសការបញ្ចុះអត្រាពន្ធនាំចូលនិងអាករពិសេស លើមុខទំនិញជាតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និង (៧)-និន្នាការកើនឡើងនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចបង្កជាហានិភ័យលើការគ្រប់គ្រងការងារប្រមូលចំណូល ។

ទី៤- ការគ្រប់គ្រងនិងការប្រមូលចំណូលមិនមែនសារពើពន្ធដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នផ្សេងៗគ្នាជាច្រើន នៅតែជួបបញ្ហាប្រឈមមួយចំនួនដូចជា : (១)-ការស្វែងរកប្រភពចំណូលថ្មីៗ នៅជួបការលំបាក ដែលចាំបាច់ត្រូវពង្កើនការសម្របសម្រួលពីអន្តរក្រសួង ស្ថាប័នទាំងដែនសមត្ថកិច្ច និងសមត្ថភាពស្ថាប័ន (២)-ការប្រមូលចំណូលមិនទាន់អស់សក្តានុពល ដែលទាមទារឱ្យមានការពិនិត្យឡើងវិញលើទិដ្ឋភាពច្បាប់ គោលការណ៍ និងយន្តការស្ថាប័នជាដើម (៣)-អាជីវកម្មកាស៊ីណូនៅតាមព្រំដែនមានស្ថានភាពបើក-បិទមិនទៀងទាត់ និង (៤)-ចំណូលពាក់ព័ន្ធនឹងវិស័យទេសចរ នៅមិនទាន់មានភាពច្បាស់លាស់ ដោយសារកត្តាពីខាងក្រៅប្រទេស ។

ខ-ផ្នែកចំណាយ

ទី១- ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ចាប់ពីដើមនីតិកាលទី៧នៃរដ្ឋសភាមក ប្រកបដោយភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ព្រមទាំងមានការប្តេជ្ញាចិត្តខ្ពស់ និងចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល បានធ្វើឱ្យហានិភ័យនៃចីរភាពថវិកា ដែលធ្លាប់តែប្រឈមដោយសារការចេះតែរីកប៉ោងធំឡើងៗនៃចំណាយបន្ទុកបុគ្គលិកត្រូវបានកាត់បន្ថយ។ ជាបច្ច័យវិជ្ជមានរាជរដ្ឋាភិបាលមានលទ្ធភាពលៃលកដំឡើងប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ និងប្រាក់សោធននិវត្តន៍ដែលឆ្លើយតបបានទៅនឹងអតិផរណា ដើម្បីរក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ត្រីជាប់កិច្ចសន្យា និងនិវត្តជន បើទោះបីជាគម្រោងចំណូលក្នុងប្រទេសមាននិន្នាការថមថយ។ ទោះជាយ៉ាងនេះក្តី ការថមថយនៃគម្រោងចំណូលឆ្នាំ២០២៥ បានធ្វើឱ្យចំណាយមិនមែនបន្ទុកបុគ្គលិកជារួមត្រូវបានកាត់បន្ថយ ខណៈដែលចំណាយមិនមែនបន្ទុកបុគ្គលិកក៏មានភាពចាំបាច់ខ្លាំងដែរ សម្រាប់សម្រេចឱ្យបានតាមគោលដៅសំខាន់ៗក្នុងការអនុវត្តកម្មវិធីនយោបាយរបស់

រាជរដ្ឋាភិបាល។ ម្យ៉ាងទៀត ការថមថយនៃគម្រោងចំណូលក៏បានដាក់បន្ទុកធ្ងន់ទៅលើចំណាយវិនិយោគសាធារណៈផងដែរដែលជាបច្ច័យ រាជរដ្ឋាភិបាលចាំបាច់ត្រូវកាត់បន្ថយថវិកាគម្រោងវិនិយោគផ្ទាល់ដើម្បីបំពេញតម្រូវការផ្នែកចំណាយចរន្ត ជាពិសេសចំណាយមិនមែនបន្ទុកបុគ្គលិក។

**ទី២**- ចំណាយគាំពារសង្គមគឺជាកម្មវត្ថុអាទិភាពខ្ពស់មួយរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅលើកកម្ពស់សមធម៌និងភាពសុខដុមរមនាក្នុងសង្គម។ យ៉ាងណាមិញ ទំហំថវិកាសម្រាប់គាំទ្រដល់គោលនយោបាយគាំពារសង្គម កាន់តែកើនឡើងជារៀងរាល់ឆ្នាំ ដែលបាននិងកំពុងដាក់ជាសម្ពាធទៅលើមុខចំណាយចាំបាច់ផ្សេងៗទៀតផងដែរ ទាំងចំណាយមិនមែនបន្ទុកបុគ្គលិក និងចំណាយវិនិយោគសាធារណៈសម្រាប់គាំទ្រដល់ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ដូចនេះ ចំណាយនៅក្នុងផ្នែកនេះ ចាំបាច់ត្រូវរៀបចំឱ្យបានចំគោលដៅនិងមានប្រសិទ្ធភាពខ្ពស់។

**ទី៣**- ការឈានឡើងរបស់កម្ពុជាពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក៏កាន់តែធ្វើឱ្យដៃគូអភិវឌ្ឍន៍មួយចំនួនទាមទារឱ្យរាជរដ្ឋាភិបាលបង្កើននូវចំណែកទឹកប្រាក់បដិភាគកាន់តែធំទៅៗ ក្នុងខណៈកាតព្វកិច្ចទូទាត់សេវាបំណុលពីគម្រោងទាំងនោះក៏ចេះតែកើនឡើងច្រើនផងដែរ បើទោះបីជាបំណុលកម្ពុជាស្ថិតក្នុងស្ថានភាពហានិភ័យកម្រិតទាបនៅឡើយក្តី។ លើសពីនេះ រាជរដ្ឋាភិបាលក៏ត្រូវទទួលកាតព្វកិច្ចរ៉ាប់រងចំពោះកម្មវិធីធំៗមួយចំនួន ដែលដល់ពេលត្រូវបញ្ចប់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

**ទី៤**- កាតព្វកិច្ចទូទាត់ចំពោះគម្រោងចំណាយធំៗដែលមានចរិតពហុឆ្នាំ ទាំងនៅក្នុងក្របខ័ណ្ឌនៃចំណាយថវិកាចរន្តនិងចំណាយវិនិយោគ បានដាក់ជាសម្ពាធដល់លទ្ធភាពថវិកាប្រចាំឆ្នាំ។ ប្រការនេះទាមទារឱ្យការសិក្សាឱ្យបានហ្មត់ចត់ គ្រប់ជ្រុងជ្រោយ ដើម្បីធានាប្រសិទ្ធភាព និងចីរភាព ព្រមទាំងអាចកាត់បន្ថយបានផលប៉ះពាល់ជាអតិបរមាទៅលើសកម្មភាពការងារផ្សេងទៀតដែលមានអាទិភាពខ្ពស់។

**ទី៥**- ធន្ធៈ និងសមត្ថភាពអ្នកទទួលខុសត្រូវ ព្រមទាំងសមត្ថភាពមានកម្រិតរបស់ស្ថាប័ននៅតែជាបញ្ហាប្រឈម នៅក្នុងដំណើរការអនុវត្តសាកល្បងថវិកាព័ត៌មានសមិទ្ធកម្ម និងការឈានទៅអនុវត្តបានមូលដ្ឋាននូវថវិកាព័ត៌មានសមិទ្ធកម្ម យ៉ាងយូរត្រឹមឆ្នាំ២០២៦។

**២១**- ក្នុងខណៈដែលស្ថានភាពសេដ្ឋកិច្ចកម្ពុជាកំពុងជួបប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិភ័យខ្ពស់ ហើយធនធានបម្រុង (ប្រាក់សន្សំ) នៃថវិកាជាតិ ក៏មានការស្រកស្រុត ដែលតម្រូវឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវប្រកាន់យកនូវជំហាននៃការអនុវត្ត គោលជំហរពង្រឹងប្រសិទ្ធភាពថវិកាជាជំហានគួបផ្សំនឹងការដាក់ចេញនូវវិធានការ ខាងផ្នែកម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសរំលេចនៅក្នុងផ្នែក II.**១** ខាងលើ រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំ និងដាក់ចេញនូវវិធានការដាក់ស្តែងមួយចំនួន ដើម្បីជម្នះប្រកបដោយប្រសិទ្ធភាព និងក្នុងលក្ខណៈជាប្រព័ន្ធនូវបញ្ហាប្រឈមទាំងឡាយផ្នែកថវិកា ដូចខាងក្រោម៖

ក-វិធានការគោលនយោបាយក្នុងការគ្រប់គ្រងចីរភាពថវិកា

**ទី១**-បន្តជំរុញអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រុងប្រយ័ត្ន ដោយប្រកាន់យកនូវបន្សំនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រយ័ត្នប្រយែងដើម្បីបន្តធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងគោលដៅធានាបាននូវអត្រាអតិផរណាក្នុងកម្រិតទាបដែលអាចគ្រប់គ្រងបាន និងស្ថិរភាពអត្រាប្តូរប្រាក់ជារួម និងសម្រេចឱ្យបាននូវស្ថិរភាពនៃកំណើន

សេដ្ឋកិច្ចខ្ពស់ដូចបានគ្រោងទុក។ រាជរដ្ឋាភិបាលក៏នឹងផ្តោតការយកចិត្តទុកដាក់លើការកែទម្រង់រចនាសម្ព័ន្ធ ជាពិសេសក្នុងវិស័យអាទិភាព ដែលជាកត្តាស្លាប់រស់ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនផលិតភាព និងជំរុញការធ្វើ ពិពិធកម្មឱ្យខ្លាំងក្លាឡើង សំដៅកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កំណើន ការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលជូនប្រជាជន និងដើម្បីទាញយកប្រយោជន៍ជាអតិបរិមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក៏ដូចជាដើម្បីទាក់ទាញការវិនិយោគពីខាងក្រៅ។

ទី២-រៀបចំវិធានការបង្កើនប្រាក់សន្សំរបស់រាជរដ្ឋាភិបាលឡើងវិញ ក្នុងគោលបំណងពង្រឹងភាពធន់ខាងហិរញ្ញវត្ថុ ដើម្បីត្រៀមទប់ទល់នឹងវិបត្តិនាអនាគត។ គួរបញ្ជាក់ថា ថវិកាឆ្នាំ២០២៥ ត្រូវបានរៀបចំលើមូលដ្ឋានតុល្យភាពនៃចំណូលនិងចំណាយ ដោយមិនមានការគ្រោងប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាលទេ។ ប៉ុន្តែ ជាទិសដៅ ចាប់ផ្តើមពីឆ្នាំ២០២៦ តទៅ រាជរដ្ឋាភិបាលគ្រោងចាប់ផ្តើមដាក់ឱ្យអនុវត្តនូវ មូលនិធិបម្រុងហិរញ្ញវត្ថុ ដែលជាមូលនិធិប្រាក់សន្សំរបស់រដ្ឋ ស្របតាមការកំណត់នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣។

ទី៣-ជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ តាមរយៈការពង្រឹងការអនុវត្ត **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥** ក្នុងគោលបំណងសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុមួយមានភាពប្រកួតប្រជែង មានសមាហរណភាព មានបទប្បញ្ញត្តិគ្រប់គ្រងនិងត្រួតពិនិត្យហ្មត់ចត់ ធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ មានការបន្សីរវាងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងជំរុញការសន្សំ។ លើសពីនេះ ការខិតខំក៏ត្រូវផ្តោតផងដែរលើការអនុវត្ត**យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥** ដោយផ្តោតការយកចិត្តទុកដាក់លើចីរភាពនិងប្រសិទ្ធភាពនៃវិស័យមីក្រូហិរញ្ញវត្ថុ ការជំរុញនវានុវត្តន៍សេវាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងការពង្រីកសមត្ថភាពប្រព័ន្ធទូទាត់ ពិសេសការទូទាត់តាមប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល ក៏នឹងផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់ការរៀបចំនិងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារឱ្យកាន់តែមានសម្ទុះរីកចម្រើនជាលំដាប់ ជាពិសេសវិស័យមូលបត្រធានារ៉ាប់រងបរធនបាលកិច្ចនិងអាជីវកម្មអចលនវត្ថុ។

ទី៤-បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពនូវ **យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០២៤-២០២៨** សំដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែងនិងកម្រិតហានិភ័យបំណុលឱ្យនៅទាប ក៏ដូចជាធានាឱ្យបាននិរន្តរភាពហិរញ្ញវត្ថុសាធារណៈនិងភាពជាម្ចាស់របស់កម្ពុជាលើការគ្រប់គ្រងជោគវាសនារបស់ខ្លួន ដោយមិនអនុញ្ញាតឱ្យប្រទេសជាតិធ្លាក់ចូលទៅក្នុងស្ថានភាពបំណុលវ័ណ្ឌកឡើយ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏នឹងជំរុញការអនុវត្តច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីលើកកម្ពស់ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការរៀបចំនិងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព ចីរភាព តម្លាភាព គណនេយ្យភាព និងយុត្តិធម៌ ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច កម្ពុជា ក៏ដូចជាការទាក់ទាញវិស័យឯកជនចូលរួមអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការផ្តល់សេវាសាធារណៈ និងការបញ្ចៀសកម្ពុជាកុំឱ្យធ្លាក់ផុងទៅក្នុងអន្ទាក់នៃថ្លៃដែលអាចកើតឡើង តាមរយៈការចុះកិច្ចសន្យា ដែលមានរយៈពេលវែង។

ទី៥-បន្តកៀរគរធនធានពីគ្រប់ប្រភពឱ្យអស់សក្តានុពល ដើម្បីតម្រង់ទៅរកការវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីទ្រទ្រង់ដល់ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ក៏ដូចជាដើម្បីលើកកម្ពស់ផលិតភាព ប្រសិទ្ធភាព ភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ដើម្បីបង្កើតការងារដោះស្រាយជីវភាព និងផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបាន ប្រាក់ចំណូលខ្ពស់ឡើងវិញ។ ក្នុងក្របខ័ណ្ឌខាងលើនេះ រាជរដ្ឋាភិបាលក៏នឹងផ្តោតការយកចិត្តទុកដាក់ផងដែរលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា។

ខ-ការពង្រឹង និងការកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ដោយក្នុងនោះ៖

(១)-ផ្នែកចំណូលពន្ធដារ ខិតខំសម្រេចឱ្យបានតាមផែនការចំណូលដែលបានកំណត់ តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយ និងវិធានការរដ្ឋបាលសារពើពន្ធ ដោយផ្តោតលើ : (ក)-ការពង្រឹងការទារបំណុលពន្ធ តាមរយៈការជ្រើសរើសបំណុលពន្ធដែលមានសក្តានុពល ជាពិសេសបំណុលរបស់អ្នកជាប់ពន្ធធំ និងអ្នកជាប់ពន្ធមធ្យមដែលមានបំណុលពន្ធចំនួនច្រើន និងមានអាយុកាលក្រោម ៣ឆ្នាំ ព្រមទាំងការជំរុញ និងការលើកទឹកចិត្តចំពោះសហគ្រាសដែលមានបំណងដោះស្រាយបំណុលពន្ធ (ខ)-ការពង្រឹងការប្រមូលចំណូលអាករពិសេសលើវិស័យផលិតស្រាបៀរនិងភេសជ្ជៈ ដោយឈរលើគោលការណ៍ប្រកួតប្រជែងដោយស្មើភាព (គ)-ការពង្រឹងយន្តការសវនកម្មពន្ធដារ ស្របតាមសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ (ឃ)-ការពង្រឹងការត្រួតពិនិត្យនិងការធ្វើសវនកម្មចំពោះសហគ្រាសក្នុងវិស័យដែលមានសក្តានុពលនិងមានហានិភ័យខ្ពស់ ដូចជា : វិស័យទូរគមនាគមន៍ អាជីវកម្មរ៉ែ និងការដឹកជញ្ជូនទំនិញ (ង)-ការជំរុញការប្រមូលចំណូលពីវិស័យល្បែងពាណិជ្ជកម្ម (កាស៊ីណូ) (ច)-ការបន្តរិះរកយន្តការដើម្បីផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែសាមញ្ញ រហ័ស ងាយស្រួល និងគ្រប់ជ្រុងជ្រោយ ព្រមទាំងមានលក្ខណៈឌីជីថល និងអនុលោមតាមឧត្តមានុវត្តន៍អន្តរជាតិ (ឆ)-ការជំរុញការរៀបចំយន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងការកំណត់អត្តសញ្ញាណអចលនទ្រព្យ សម្រាប់អចលនទ្រព្យគម្រោងបុរី និង (ជ)-ការអនុវត្តពន្ធលើចំណេញ មូលធនលើទ្រព្យ៥ប្រភេទ រួមមាន : កតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយវត្ថុបរទេស នៅក្នុងឆ្នាំ២០២៥។

(២)-ផ្នែកចំណូលគយនិងរដ្ឋាករ ខិតខំសម្រេចឱ្យបានតាមផែនការចំណូលដែលបានកំណត់ តាមរយៈការដាក់ចេញនូវវិធានការ : (ក)-ការបន្តពង្រឹងការងារបច្ចេកទេសគយ និងប្រសិទ្ធភាពនៃការប្រមូលចំណូល ដូចជា : តាមរយៈការពង្រឹងការអនុវត្តយន្តការវាយតម្លៃហានិភ័យធុរជន និងទំនិញ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងការអនុវត្តអត្រាពន្ធអនុគ្រោះ ក្រោមក្របខ័ណ្ឌនៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការពង្រឹងអនុលោមភាពលើការនាំចូលទំនិញដែលទទួលបានការលើកទឹកចិត្តពន្ធ និងអាករ ក្រោមក្របខ័ណ្ឌគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (ខ)-ការបន្តពង្រឹងការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម និងគោលនយោបាយពន្ធគយ ដូចជា : តាមរយៈការពង្រឹង

យន្តការកិច្ចសម្រួលពាណិជ្ជកម្ម ដោយធ្វើសាមញ្ញកម្មនីតិវិធីគយ ការកែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងប្រតិបត្តិការគយ និងការជំរុញការអនុវត្តបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក និងការពង្រីកវិសាលភាព និងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ និង (គ)-ការបន្តពង្រឹងសមត្ថភាពស្ថាប័ននិងអភិបាលកិច្ច ដូចជា : តាមរយៈការបន្តពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ការបន្តធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងការពង្រឹងការងារសវនកម្មផ្ទៃក្នុង។

(៣)-ផ្នែកចំណូលមិនមែនសារពើពន្ធ ជំរុញ និងពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ក៏ដូចជាការបន្តស្វែងរកមុខចំណូលថ្មីៗ និងការពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលដែលមានស្រាប់។ លើសពីនេះ រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការបន្ថែមមួយចំនួន រួមមាន : (ក)-ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការរៀបចំផែនការទាក់ទាញទេសចរមកកាន់ខេត្តសៀមរាប (ខ)-ការបន្តពង្រឹង និងជំរុញការគ្រប់គ្រងការប្រមូលចំណូលពីវិស័យទេសចរណ៍ ដោយការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេសការទិញប័ណ្ណចូលទស្សនារមណីដ្ឋានអង្គរ ដោយកែសម្រួលប្រព័ន្ធត្រួតពិនិត្យដែលមានភាពសាំញ៉ាំមកជាប្រព័ន្ធមានភាពងាយស្រួល (គ)-ការបន្តពង្រឹងយន្តការ និងប្រសិទ្ធភាពនៃការប្រមូលចំណូលពីវិស័យធនធានរ៉ែឱ្យអស់សក្តានុពល ជាពិសេសផលិតផលរ៉ែនាំចេញទៅក្រៅប្រទេស (ឃ)-ការបន្តចាត់វិធានការតឹងទារបំណុលក្នុងវិស័យរ៉ែ និងវិស័យទូរគមនាគមន៍ (ង)-ការបន្តជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យកាន់តែមានប្រសិទ្ធភាព សក្តិសិទ្ធិភាព និងគណនេយ្យភាព រួមទាំងការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក ជាដើម។

**គ- ការពង្រឹង និងការកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណាយ**

រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើ៖

-ការបន្តពង្រឹង និងកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណាយប្រកបដោយភាពប្រយ័ត្នប្រយែង និងបុរេសកម្មខ្ពស់ ដោយឈរលើគោលការណ៍គោរពម៉ឺងម៉ាត់វិន័យថវិកា និងពង្រឹងប្រសិទ្ធភាពថវិកា ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ តាមរយៈការបន្តខិតខំកែលម្អការវិភាជថវិកាឱ្យកាន់តែចំទិសដៅ និងចំតម្រូវការចាំបាច់ជាក់ស្តែង ព្រមទាំងការបង្កើនការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយអាទិភាពគន្លឹះ និងតាមវិស័យរបស់រាជរដ្ឋាភិបាល ជាពិសេសផ្តល់អាទិភាពចំណាយលើកិច្ចការកែទម្រង់។

-ការបន្តផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយឱ្យនៅខ្លី និងបង្កើនការទម្លាក់ថវិកាដល់ដៃអ្នកអនុវត្តការងារផ្ទាល់ ព្រមទាំងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងចំណាយចរន្ត និងចំណាយមូលធន ទាំងចំណាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាថា រាល់ចំណាយត្រូវបានធ្វើឡើងដោយមានតម្លាភាព និងគណនេយ្យភាព ក្នុងថ្លៃសមរម្យ និងគុណភាពសមស្រប ក្នុងបរិមាណដែលត្រូវការចាំបាច់ជាក់ស្តែង និងទាន់ពេលវេលាដែលត្រូវការប្រើប្រាស់។

-ការបន្តយកចិត្តទុកដាក់ខ្ពស់ ដល់ការអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក៏ដូចជាផែនការសកម្មភាពដែលទើបបានធ្វើបច្ចុប្បន្នភាពសម្រាប់អនុវត្ត យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ព្រមទាំង យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥ តាមរយៈការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តសាកល្បងថវិកាព័ត៌មានសមិទ្ធកម្ម ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ ដែលជាអនុក្រឹត្យគោលសម្រាប់ការអនុវត្តថវិកា ព្រមទាំងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលនៅសេសសល់ ដើម្បីធានាការអនុវត្តជាមូលដ្ឋាននូវថវិកាសមិទ្ធកម្មយ៉ាងយូរត្រឹមឆ្នាំ២០២៦។

-ការបន្តពង្រឹងកិច្ចលទ្ធកម្មសាធារណៈ សំដៅបង្កើនប្រសិទ្ធភាពនិងតម្លាភាពនៃចំណាយសាធារណៈ ជាពិសេសបង្កើនតម្លៃនៃលុយ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រនៃការទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ និងច្បាប់លទ្ធកម្មសាធារណៈឆ្នាំ២០២៣។ រាជរដ្ឋាភិបាលនឹងពិនិត្យតាមតម្រូវការចាំបាច់ ដើម្បីចាត់វិធានការដាក់ស្លែងមួយចំនួនទៀត ដោយប្រទាក់ក្រឡាជាមួយនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ សំដៅពង្រឹងអភិបាលកិច្ចនៅក្នុងការគ្រប់គ្រងចំណាយសាធារណៈ។

-ការបន្តជំរុញការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិជាពិសេសការបន្តពង្រឹងសមត្ថភាពផ្នែករដ្ឋបាល បច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុ របស់គ្រប់ស្ថាប័ននិងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការផ្ទេរសិទ្ធិអំណាចការទទួលខុសត្រូវមុខងារ និងធនធានពីថ្នាក់ជាតិ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល ដើម្បីធានាសុខដុមនីយកម្ម រវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

## IV- **បទប្បញ្ញត្តិស្តីពីពន្ធដារ**

**២២**- អនុលោមតាមមាត្រា១៩៦ នៃច្បាប់ស្តីពីសារពើពន្ធ រាជរដ្ឋាភិបាលមានកាតព្វកិច្ចធ្វើនិយ័តកម្មវូបនីយកម្ម តាមរយៈច្បាប់ហិរញ្ញវត្ថុនូវបណ្តាវិធានការពាក់ព័ន្ធនឹងការអនុគ្រោះ ឬការលើកលែងពន្ធអាករនានា ដែលត្រូវបានសម្រេចដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល ក្នុងអំឡុងឆ្នាំ២០២៣ រហូតដល់ដំណាច់ឆ្នាំ២០២៤ ដូចមានបញ្ជីនៃលិខិតបទដ្ឋានគតិយុត្តជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី៤**។ វិធានការទាំងនេះត្រូវបានធ្វើឡើងក្នុងគោលបំណង ដូចខាងក្រោម៖

-គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជួយសម្រាលបន្ទុកជីវភាពរបស់ប្រជាពលរដ្ឋ ពិសេសតាមរយៈការជួយកាត់បន្ថយចំណាយលើសាច់សត្វដែលជាអាហារមូលដ្ឋានចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ

-ផ្តល់ការធានា និងការលើកទឹកចិត្តដល់ប្រជាជនដែលប្រកបរបរជាសហគ្រាសធុនមីក្រូ ធុនតូច និងសហគ្រាសធុនមធ្យមដែលប្រកបអាជីវកម្ម ដូចជា : ការលក់ដុំ លក់រាយ និងជួសជុល សេវាកម្មស្នាក់នៅនិងអាហារ សិប្បកម្ម និងសហគមន៍កសិកម្ម

-បង្កើនជំនឿទុកចិត្តដល់វិនិយោគិននិងតម្រូវការទីផ្សារក្នុងរយៈពេលខ្លី មធ្យម និងរយៈវែង សម្រាប់ដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ តាមរយៈការដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុឆ្នាំ២០២៤

-លើកទឹកចិត្តពន្ធដារចំពោះវិស័យកសិកម្ម ដើម្បីជួយជំរុញវិស័យកសិកម្ម និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា

-ជំរុញការអភិវឌ្ឍធនធានមនុស្សនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកទឹកចិត្តពន្ធដារចំពោះវិស័យអប់រំ

-ព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរ ដែលទទួលបានលក្ខណសម្បត្តិជាគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីឱ្យមាននិរន្តរភាព និងជាការគាំពារដល់កម្មករកម្មការិនី ព្រមទាំងប្រជាពលរដ្ឋដែលទទួលផលប្រយោជន៍ពីវិស័យនេះ និងជំរុញការនាំចេញ

-ជួយស្តារវិស័យទេសចរណ៍ឱ្យបានប្រសើរឡើងវិញ ស្របតាមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដោយផ្តល់ការលើកទឹកចិត្តចំពោះវិស័យទេសចរណ៍

-គាំទ្រវិធានការដែលរាជរដ្ឋាភិបាលបានដាក់ចេញនៅក្នុងអង្គវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ និងស្របទៅនឹងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដោយបន្តលើកលែងពន្ធអប្បបរមា ដល់សហគ្រាសជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

-លើកស្ទួយវិស័យសារព័ត៌មានកាសែតនិងសារព័ត៌មានអនឡាញនៅកម្ពុជា តាមរយៈការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារដោយចាត់ទុកជាបន្ទុករបស់រដ្ឋនូវពន្ធប៉ាតង់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៨ ដល់អ្នកសារព័ត៌មានកាសែត និងសារព័ត៌មានអនឡាញជាអ្នកជាប់ពន្ធតូច

-គាំទ្រការសម្រេចរបស់រាជរដ្ឋាភិបាលបានដាក់ចេញនៅក្នុងអង្គវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៩ តាមរយៈការបន្តគោលការណ៍លើកលែងពន្ធ ការអនុគ្រោះពន្ធបន្ថែមទៀត ការពន្យារ និងការព្យួរ ការអនុវត្តពន្ធសម្រាប់វិស័យអចលនទ្រព្យ

-សម្រួលដល់អ្នកជាប់ពន្ធដែលមានឆន្ទៈក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ និងជំរុញការចុះបញ្ជីពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ឱ្យអស់សក្តានុពល តាមរយៈការលើកលែងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែមនិងការប្រាក់) ចំពោះពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់។

## V- សេចក្តីសន្និដ្ឋាន

**២៣**- ក្របខ័ណ្ឌថវិកាឆ្នាំ២០២៥ ត្រូវបានរៀបចំឡើងដោយប្រកាន់យក **ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន** ក្នុងគោលដៅដោះស្រាយឱ្យបានជាសារវន្តនូវសេចក្តីត្រូវការ ក្នុងការឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយធំៗរបស់រាជរដ្ឋាភិបាលនិងតម្រូវការចាំបាច់ជាមូលដ្ឋាន

របស់ក្រសួង ស្ថាប័ននានា ដើម្បីបម្រើនិងផ្តល់នូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងការទន្ទឹងរង់ចាំ និងបំណងប្រាថ្នារបស់ប្រជាជន ជាពិសេសការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែង ប្រកបដោយប្រសិទ្ធភាពនូវ **កម្មវិធីនយោបាយ** និង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល ដែលជាមាគ៌ារយៈពេលមធ្យមមួយ ដើម្បីឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិ និងកសាងជាតិមួយដ៏រស់រវើក មានអនាគតដ៏រុងរឿង ភ្លឺស្វាង និងត្រចះត្រចង់ ជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យនិងនីតិរដ្ឋ មានសន្តិភាព មានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ ព្រមទាំងជាប្រទេសមានចំណូលខ្ពស់ នាពេលអនាគត មានសេដ្ឋកិច្ចរឹងមាំ ធន់នឹងវិបត្តិ និងមានសង្គមបរិយាបន្ន។ ក្របខ័ណ្ឌថវិកាខាងលើនេះ ក៏មានគោលដៅធានារក្សានូវសមិទ្ធផលនៃការអភិវឌ្ឍទាំងពួងដែលសម្រេចបាននៅក្នុងនីតិកាលមុនៗកន្លងមក ជាពិសេសការរក្សាការពារឱ្យបានដាច់ខាតនូវសន្តិភាព និងអធិបតេយ្យភាពរបស់កម្ពុជា ក្នុងឋានៈជារដ្ឋមួយដែលមានឯករាជ្យភាពពេញបរិបូណ៌និងការខំប្រឹងងើបឈរឡើង ដើម្បីធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួនដោយខ្លួនឯង ទាំងនៅក្នុងអតីតកាល បច្ចុប្បន្ននិងតទៅអនាគត។

**២៤**- ថវិកាឆ្នាំ២០២៥ នឹងដើរតួនាទីជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការរក្សា ការការពារ និងការពង្រឹងថែមទៀតនូវសមិទ្ធផលដ៏ធំធេងដែលកម្ពុជាសម្រេចបានកន្លងមក ក៏ដូចជាក្នុងការបន្តបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត។ អាទិភាពចំណាយថវិកាឆ្នាំ២០២៥ គឺជាការឆ្លើយតបទៅនឹងអាទិភាព និងតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ននានា ជាពិសេសការផ្សារភ្ជាប់សកម្មភាពអនុវត្តការងារប្រចាំថ្ងៃទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ក៏ដូចជាគោលនយោបាយជាអាទិភាពរួមរបស់រាជរដ្ឋាភិបាល ដែលរួមមាន : ការពង្រឹងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍមូលធនមនុស្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការជួសជុលនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេសការបង្កើតតម្លៃបន្ថែមក្នុងវិស័យចន្ទល់សេដ្ឋកិច្ចដែលមានស្រាប់និងអនុវិស័យពាក់ព័ន្ធការជំរុញការវិនិយោគក្នុងវិស័យកសិកម្ម ការរៀបចំខ្លួនសម្រាប់ឈោងចាប់យកបច្ចេកវិទ្យាថ្មីៗក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល ការពង្រីកវិសាលភាព និងការពង្រឹងគុណភាពនៃសេវាសាធារណៈគ្រប់ប្រភេទ ជាពិសេសសេវាអប់រំ សេវាសុខាភិបាល សេវាយុត្តិធម៌ និងសេវាមូលដ្ឋានចាំបាច់ដទៃទៀត និងការកែទម្រង់អភិបាលកិច្ច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងការអនុវត្តរបបគាំពារសង្គម ដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធម៌សង្គម ចីរភាព និងភាពអាចទ្រទ្រង់បាននៃថវិកា។ ទន្ទឹមនេះ ថវិកាឆ្នាំ២០២៥ ក៏បានគូសបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការខិតខំបង្កើនប្រសិទ្ធភាព និងកម្រិតនៃការកៀរគរចំណូលគ្រប់ប្រភេទ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំណាយខាងលើ តាមរយៈការដាក់ចេញឱ្យបានឆាប់និងការជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវ **យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០២៤-២០២៨** ដែលជាមូលដ្ឋានសម្រាប់ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល ក៏ដូចជាដើម្បីធ្វើឱ្យប្រព័ន្ធចំណូលជាតិក្លាយទៅជាឃ្នាស់សេដ្ឋកិច្ចមួយយ៉ាងពិតប្រាកដ ដោយបន្តផ្សារភ្ជាប់ការគិតគូរ និងការយកចិត្តទុកដាក់ទៅដល់អ្នកមានចំណូលទាបនិងអាជីវកម្មតូចតាច។

សរុបមក ថវិកាឆ្នាំ២០២៥ អាចត្រូវបានប្រសិទ្ធនាមថាជា "ថវិកានៃការបោះជំហានទៅមុខយ៉ាងស្វាហាប់ ប្រកបដោយឆន្ទៈមោះមុតនិងការប្ដូរប្ដេជ្ញ ក្នុងការឆ្លងកាត់និងជម្នះ លើរាល់បញ្ហាប្រឈម និងឧបសគ្គផងទាំងពួង ឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ក្រោមម្លប់នៃសុខសន្តិភាព ដើម្បីជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយភាពធន់ បរិយាបន្ន និងមានចីរភាព ព្រមទាំងបែងចែកផលនៃកំណើននេះប្រកបដោយសមធម៌"។

**២៥**- ក្នុងន័យនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តមុតមាំក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ដែលបានលើកឡើងខាងលើនេះ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ប្រសិទ្ធភាពថវិកា ទាំងក្នុងកម្រិតវិភាជន៍ ទាំងក្នុងកម្រិតប្រតិបត្តិការ ក៏ដូចជាប្រកាន់ខ្ជាប់នូវអភិក្រមការងារ៥យ៉ាង គឺឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ ដើម្បីធានាឱ្យបាននូវសន្តិភាព ស្ថិរភាព វឌ្ឍនភាព និងវិបុលភាព សម្រាប់បំពេញតាមបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងដើម្បីបង្កើតឡើងនូវបុរេលក្ខខណ្ឌចាំបាច់និងបរិស្ថានអនុគ្រោះ សំដៅកសាងមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់ដំណើរការផ្លាស់ប្ដូរស៊ីជម្រៅរបស់កម្ពុជាឈានទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនារបស់ប្រទេសជាតិ និងឈរលើគោលការណ៍តម្កល់ផលប្រយោជន៍ជាតិខ្ពស់បំផុត និងប្រជាជនជាធំ ដើម្បីជម្នះបាននូវបញ្ហាប្រឈម និងឧបសគ្គទាំងឡាយ សំដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ ដើម្បីស្នើសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ដែលរួមមាន៦ជំពូក និងមាន១៥មាត្រា ដូចខាងក្រោម៖

- **ជំពូកទី១ មាន ៥ មាត្រា (ពីមាត្រា១ ដល់មាត្រា៥)**
  **ជំពូកទី១នេះ កំណត់អំពីថវិកាថ្នាក់ជាតិ**
- **ជំពូកទី២ មាន ៤ មាត្រា (ពីមាត្រា៦ ដល់មាត្រា៩)**
  **ជំពូកទី២នេះ កំណត់អំពីការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី និងការធានារបស់រដ្ឋ**
- **ជំពូកទី៣ មាន ១ មាត្រា (មាត្រា១០)**
  **ជំពូកទី៣នេះ កំណត់អំពីបទប្បញ្ញត្តិស្តីពីពន្ធដារ**
- **ជំពូកទី៤ មាន ១ មាត្រា (មាត្រា១១)**
  **ជំពូកទី៤នេះ កំណត់អំពីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**
- **ជំពូកទី៥ មាន ២ មាត្រា (ពីមាត្រា១២ ដល់មាត្រា១៣)**
  **ជំពូកទី៥នេះ កំណត់អំពីពិតានចំនួនបុគ្គលិកស៊ីវិល**
- **ជំពូកទី៦ មាន ២ មាត្រា (ពីមាត្រា១៤ ដល់មាត្រា១៥)**
  **ជំពូកទី៦នេះ កំណត់អំពីអវសានប្បញ្ញត្តិ។**

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ត្រូវបានរៀបចំឡើងតាមទម្រង់បង្ហាញស្របតាមការកំណត់ក្នុងមាត្រា៥៩នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏នៅមានតារាងឧបសម្ព័ន្ធខ្លះទៀតដែលត្រូវការពេលដើម្បីរៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗស្របតាមមាត្រា១០៧នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ថ្ងៃ សុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# ឧបសម្ព័ន្ធទី១

## ចំណូល-ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

ឯកតា:លានរៀល

| បរិយាយ | ផែនការ ឆ្នាំ២០២៥ |
|---|---|
| I- **សរុបធនធាន** | **7.327.543,4** |
| **១-ចំណូល** | **3.679.822,2** |
| ក- ចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិ | 582.310,2 |
| -សម្រាប់បន្ទុកបុគ្គលិក | 220.027,2 |
| -សម្រាប់ចំណាយទូទៅ | 362.283,0 |
